ការធំចំរើនឡើងក្តី ការចាស់ជរាក្តី ការស្លាប់បាត់ទៅវិញក្តី ជាផលដែលកើតឡើងពីហេតុផ្សេងមួយចំណែក ៗ យ៉ាងណា ជាតិរបស់មនុស្សក៏យ៉ាងនោះដែរ កាលជាតិមួយចំរើនធំឡើង កាលមកជាខាងក្រោយក៏ត្រឡប់ជាវិនាសទៅវិញ រហូតដល់រលត់រលាយជាតិ តែរឿងនេះយើងនឹងទុកដាក់ថា ការដែលជាតិកើតឡើងជាហេតុឲ្យចំរើន ការដែលជាតិចំរើនជាហេតុឲ្យជាតិចុះថយ ហើយការដែលជាតិចុះថយជាហេតុឲ្យជាតិរលត់រលាយទៅវិញដូច្នេះតំរូវ ៗ យើងត្រូវចូលចិត្តថា ការចំរើន ការចុះថយ និងការរលត់ជាតិនោះ សុទ្ធតែជាផលរបស់ហេតុ ដែលមានមកពីហេតុផ្សេង ៗ តែមិនមែនជាហេតុផលរបស់ខ្លួន និងខ្លួន ក្នុងខ្លួនឡើយ ។

បើយើងយល់សេចក្តីនេះច្បាស់លាស់ ទើបយើងឃើញប្រយោជន៍ក្នុងការរៀនប្រវត្តិសាស្ត្រ ។ ក្នុងវេលានេះ ព្រះពុទ្ធ-សាសនានៅប្រទេសខ្មែរយើង កំពុងឡើងកាន់សេចក្តីចំរើន

ហើយប្រុងនឹងលូតលាស់ចំរើនតទៅមុខទៀត  យើងត្រូវការពារឲ្យគង់វង្ស សាសនា ចំរុងចំរើនជឿនលឿនជាលំដាប់តទៅ យើងត្រូវព្យាយាមរក្សាសេចក្ដីចំរើនទាំងនោះ  ទុកឲ្យបានឋិតថេរចីរកាលយូរបំផុត  ដែលនឹងអាចឋិតយូរទៅបាន  កាលបើដូច្នេះ  តើយើងត្រូវធ្វើដូចម្ដេច ?

តបឆ្លើយ ៗ តាមគោលអរិយសច្ច នាំយើងត្រូវដឹងហេតុនៃសេចក្ដីចំរើន  និងហេតុនៃសេចក្ដីវិនាស ។

បើដូច្នោះ  តើយើងត្រូវដឹងបានដោយប្រការដូចម្ដេច ?

ថាយើងត្រូវដឹងដោយការសិក្សាប្រវត្តិសាស្ត្រ ។

ប្រវត្តិសាស្ត្រជាឯកសារ  ដែលពណ៌នាហេតុការណ៍នៃលោកតាំងតែ ៧០០០ ឆ្នាំមកហើយ  មានជាតិ  មានភាសាដែលកើតឡើង  ចំរើនឡើង  ទន់ថយទៅ  ហើយសាបសូន្យរលត់បាត់បង់ទៅវិញដោយច្រើន  ការកើតឡើងក្ដី  ការចំរើនការទន់ថយក្ដី  ការរលត់រលាយបាត់បង់ទៅវិញក្ដី  តែងមាន

ហេតុច្រើនប្រការផ្សេងៗគ្នា ហើយយើងគប្បីប្រមូលយកតែសេចក្ដីល្អៗ មកប្រើជាគ្រឿងថៃ ទុកជាឧទាហរណ៍សម្រាប់ការពារជាតិសាសនារបស់យើង កុំឲ្យកើតហេតុខៃការលេកលោយលាញទៅវិញបានឡើយ ។

សេចក្ដីពិតមួយទៀត យើងគួរចងចាំទុកថា ហេតុការណ៍ទាំងអស់ក្នុងលោកនេះ តែងតែវិលត្រឡប់ទៅរករបស់ចាស់វិញជាដរាប ហេតុផល់កើតជាពាក្យសុភាសិតឡើងប្រចាំថា "ប្រវត្តិសាស្ត្រ និយាយតែពីរឿងដដែលៗ" ។

x

x x

# ១_សភាពនយោបាយប្រទេសឥណ្ឌា· ប្រទេស

ឥណ្ឌា ទុកជាលោកមួយដោយឡែក នៅពេលដែលម្នាក់ឯង មានកាយធំមួយផ្សេង ដាច់ពីប្រទេសទូទៅនៃសកលលោក ព្រោះភូមិសាស្ត្រឥណ្ឌាជាមហាឧបទ្វីប គឺជាប្រទេសមួយធំ មានភ្នំធំស្ទើបស្ទើនៃពិភពលោក ញែកឲ្យដាច់ចេញពីលោកដទៃ ៗ តែទោះដូចម្ដេចក្ដី គង់លោកនេះ មុខហានណាក៏ដោយ តែងមានការលុកលុយពីបរទេស តាំងតែពីកាលមុនគ្រិស្តសករាជ ទិសនិរតី តែមិនឲ្យមានការយំធំរើបុំដូចឥណ្ឌាដែលឆ្ងាយ ទូទៅដូចគេះបន្ទាន់ឡើយ ព្រោះភូមិសាស្ត្រប្រទេសនេះ មានភ្នំនិងសមុទ្រព័ទ្ធជុំវិញ ។ ដើមឡើយ ប្រទេសឥណ្ឌានេះ មានពួកអារ្យ៉ន (Aryan) ចូលមកលុកលុយច្រើនលើកហើយ ក្រៅពីអារ្យ៉ន មានពួក ពែរ្ស ក្រិក សក (Saka) គុសាន (Kusâna) ហ៊ុន (Huns) អារ៉ាប់ តួរគី ម៉ុងហ្គោល និងអឺរ៉ុប ៗ

ប្រទេសដែលបានទទួលវប្បធម៌ឥណ្ឌាគឺ អាស៊ីកណ្ដាល ចិន (គតិចិនទៅជប៉ុន) និងទីបេ (គតិទីបេទៅម៉ុងហ្គោលី) ប្រទេសអាស៊ីអាគ្នេយ៍ ទាំងអស់នេះសុទ្ធតែបានទទួលយកសាសនា ទស្សនវិជ្ជា វិទ្យាសាស្ត្រ មន្តអាគម ព្រមទាំងវិជ្ជាបរទេសពីប្រទេសឥណ្ឌា ។ ឯប្រទេសឥណ្ឌា ទទួលយកលទ្ធិបារសី (Pārsi = Perse) ជ្វីហ្វ គ្រិស្ត និងឥស្លាម ដែលបរទេសនាំចូលមកនៅដែនដីឥណ្ឌា តែប្រទេសឥណ្ឌាក៏បានរក្សាទុកនៅភាពដើមរបស់ខ្លួន ទេពកោសល្យខ្លួន ដើម្បីទប់ទល់ចំពោះឥទ្ធិពលបរទេសទាំងនោះបានគង់បានតរឿយ ៗ

ការនិយាយថា ប្រទេសឥណ្ឌានៅពេលតែម្នាក់ឯងនេះ នៅក្នុងបច្ចុប្បន្នកាលនេះ គេទុកជារឿងត្រឹមទេ ប៉ុន្តែការនិយាយថានៅពេលនោះ បើនិយាយតាមផែនដីសាពេប ជាការនៅពេលយូរយារណាស់ ព្រោះព្រះបាទការទៀតសង្គ្រាមហា

រាជវង្សព្រះរាជាសេឡឺស៊ីដ[១] (Séleucides) បានលុកលុយទៅដល់ប្រទេសឥណ្ឌាភាគខាងលិចហើយ តែមិនទុកជាជាស្ថានទួនគឺកេប-ឥណ្ឌាឲ្យនៅឋិតថេរពុំបានឡើយពួកវង្សសស្សានិដ (Sessanides) ពួកភាគប៉ តមកពួកឥស្លាម ក៏បានចូលទៅដល់ប្រទេសឥណ្ឌាដែរ តែការទៅដល់នេះ ត្រឡប់ទៅជាកំពែងការពារ ៗ មិនឲ្យឥទ្ធិពលក្រៅចូលទៅដល់ប្រទេសឥណ្ឌាវិញ ថែមទាំងមិនឲ្យផលិតផលប្រទេសឥណ្ឌា ចូលទៅអឺរ៉ុបទៀតផង ។ ហេតុនេះហើយបានជាគេនិយាយថា ប្រទេសឥណ្ឌានៅពេលតែម្នាក់ឯង ក្រៅពីប្រវត្តិសាស្ត្រទូទៅ ។

អារ្យធម៌ឥណ្ឌា គឺជាសារពើត្រែនៃហេតុការណ៍មនុស្សលោក ជាអារ្យធម៌មួយដែលផ្សាយទូលំទូលាយណាស់ ។ លោកពោលទុកថា ប្រវត្តិសាស្ត្រឥណ្ឌានេះ ជាអារ្យធម៌មួយ

---

១ រាជវង្សដែលតាំងឡើងនៅប្រទេសស៊ីរី (Syrie) ដោយព្រះរាជវង្សសេឡឺកូស (Séleucos) ទីមួយ ពីឆ្នាំ ៣១២ មក ៦៤ មុនគ្រិស្តសករាជ ។

ចំណែកឯប្រវត្តិសាស្ត្រទូទៅ នៃសកលលោក ជាកាយធម៌មួយចំណែកផ្សេងទៀត ៗ ដោយបានផ្សាយលទ្ធិសាសនា វិទ្យាសាស្ត្រពេញអាស៊ីទ្វីប អាស៊ីអាគ្នេយ៍ ក្នុងជាក្រុមប្រវត្តិសាស្ត្រមួយ ដូចកាយធម៌ហិល្លេន (កាយធម៌ក្រិក) គ្រិស្ត និងឥស្លាមដែរ ៗ

២ អារ្យ័នចូលមកប្រទេសឥណ្ឌា- អារ្យ័ន ក្នុងគម្ពីរអវេស្តា គេសរសេរថា អៃរ្យ៍ (Airya) សំ. អារ្យៈ (Arya) ពួកអារ្យ័ននេះចុះពីកំពូលលោក មកដល់ប្រទេសនៃទន្លេសិន្ធុមុនដំបូង គឺប្រទេសសប្តសិន្ធុសិ ដែលគម្ពីរអវេស្តាជាភាសាផារ៉ស៊ីសរសេរថា "ហប្ត ហិណ្ឌុ" តមក គេហៅថា "បញ្ចនទ= ស្ទឹងប្រាំ" វិញ តែភាសាបារាំងសព្វថ្ងៃនេះ ហៅក្លាយទៅជាបញ្ចាប (Panjab) គឺបញ្ច + អាប=ស្ទឹងប្រាំ ៗ

គម្ពីរឫគ្វេទនិយាយថា អារ្យ័ន ធ្វើចំបាំងនឹងកុលសម្ពន្ធទស្យុ,ទាស ដែលជាជនអ្នកដើមស្រុក ៗ មុនសម័យព្រាហ្មណៈ

រឿងដែលនិយាយថា សមុទ្រ "ទីប្រមូលទឹក" ដែលតំខ្ជុំ ដែលមានលិចមិនទាន់កើត មិនឃើញមានសេចក្តីពិតទេ ។ ពាក្យដែលគេនិយាយថា "បញ្ចាប" នេះ ក៏មាននៅក្រោយគម្ពីរវេទដែរ គឺស្ទឹង វិតស្តា សព្វថ្ងៃហៅ ឈេល័ម=ឈេលុម (Jhelam). គឺ អសិក្នី (Asikni) សព្វថ្ងៃនេះហៅថា ចនាប (Cenab). បរុស្នី (Perusni) គេបានហៅថា ឥរាវតី (I[illegible]ti) សព្វថ្ងៃនេះហៅថា រាវី (Ràvi) ទៅវិញ, វិបាស (Vipac) សព្វថ្ងៃហៅព្យាស (Byàs) , កុតុទ្រី (cutudri) សព្វថ្ងៃហៅថា សត្លុជ (Sattlaj) ។ ស្ទឹងសំខាន់ជាងគេគឺស្ទឹង សរស្វតី (Saresvati) មានក្រៅទុកក្នុងគម្ពីរវេទ សព្វថ្ងៃនេះប្រហែលជាស្ទឹង សរស៊ុតី (Sarsuti) ឋិតនៅចន្លោះស្ទឹងសត្លុជ និងស្ទឹងជម្នា ព្រោះមានសល់ដំណែលនៅឡើយ ។ ស្ទឹងសរស្វតី និងទន្លេសិន្ធុនេះ ព្រមទាំងដៃប្រាំផង ទៅជា សប្តសិន្ធុ-វេ= ស្ទឹងឬទន្លេប្រាំពីរ ។ ឯទន្លេជម្នាគឺយមុនានេះ គម្ពីរ

វេទមិនសូវមាននិយាយដល់ទេ មាននិយាយតែម្តងប៉ុណ្ណោះ ។

ជនជាតិអារយ៌នដែលមាននិយាយថា ច្បាំងគ្នាឯងនោះ(១) គឺពួកអារយ៌ន = ភារតនេះឯង ព្រោះមានឈ្មោះប្រាកដក្នុងគម្ពីរបុរាណ តមកដែនដីភារតក៏បានក្លាយទៅជា "ភារតវើស" ជាឈ្មោះដែលជនហិណ្ឌូហៅស្រុកខ្លួននេះ ។ រឿងដែលមានដំណាលទុកថា ចម្បាំងព្រះបាទសុទាសិ (Sudās) នៃពួកភារតនោះ មិនសូវមាននិយាយក្នុងគម្ពីរវេទប៉ុន្មានទេ ។ ចម្បាំងក្នុងការនោះ ជាចម្បាំងមួយដោយឡែក ឯរឿងដំណើរប្រជែងគ្នានៃបុរោហិត គឺវិស្វាមិត្រ វសិស្ឋ គាយកនៃព្រះបាទសុទាសិ ដែលមានប្រាកដក្នុងគម្ពីរវេទដែរនោះ ក៏គ្រាន់តែជារឿងនិយាយផ្សេង ១ ទៀត ក្នុងកាលដែលព្រះបាទសុទាសិ

---

១–កុលសម្ពន្ធក្នុងគម្ពីរវេទ នៅខាងកើតទន្លេ ឝុទុទ្រី (çutudri) គឺព្រះរាជាព្រះនាម សុទាសិ នៃត្រកូលត្រិត្សុ (Tritsu) មានព្រាហ្មណ៍វសិស្ឋជាបុរោហិត បានច្បាំងឈ្នះព្រះរាជា ៦ អង្គដែលមានព្រាហ្មណ៍ វិស្វាមិត្រ ជាបុរោហិត ។

ដាក់បន់ទៅហើយ  គឺគ្រាន់តែមានក្រាទុកក្នុងគម្ពីរឫគ្វេទដើម្បី ដំណាលរឿងបុរាណតែប៉ុណ្ណោះទេ ។

បន្ទាប់ពីគម្ពីរឫគ្វេទមក  មានគម្ពីរយជុរវេទ  និងអថវ៌វេទ កើតឡើង ៗ ក្នុងសម័យនេះ  វប្បធម៌វេទ  បានចូលមកដល់ ប្រទេសឥណ្ឌាទៅភាគខាងកើតនិងខាងត្បូងហើយ ៗ ជនកុរុ ឬហៅថាកៅរវៈ  (ដែលជាតំណពូជពង្សមកពីភារតនិងបុរុ = Puru ហើយជាសត្រូវនឹងគ្នាតាំងពីសម័យឫគ្វេទ) រួមគ្នានឹង ជនបញ្ចាល ហៅថា កុរុបញ្ចាល  ពួកនេះតាំងទីឋាននៅតំបន់ ចន្លោះគង្គានិងយមុនាភាគខាងលើ  ហៅថាតំបន់ ទោ·អាប (Do-ab) សព្វថ្ងៃនេះ ៗ រឿងពួកកុរុនិងព្រះបាទបរិក្សិត (Pariksit)  ដែលមានក្រាទុកក្នុងសម័យអថវ៌វេទ  គឺជារឿង ព្រេងនាយដែរ ព្រោះមានក្រាទុកនៅតែក្នុងគម្ពីរព្រហ្មណារណ្យ-កោបនិសទ  ក្នុងពេលខ្សែនេះទៅវិញ ៗ រឿងមហាភារត ដែលតែងឡើងក្រោយសម័យវេទ  ក៏មាននិយាយពីពូជពង្ស

កៅរវៈនិងបាណ្ឌវៈធ្វើសង្គ្រាមដែរ ដែលហៅថាមហាភារតយុទ្ធ ហើយកាលជាខាងក្រោយនៃមហាសង្គ្រាមនេះ ទើបព្រះបាទបរិក្សិតកើតឡើង ។ រីឯសង្គ្រាមនេះ បើតាមគម្ពីរបុរាណៈនិយាយថា កើតនៅឆ្នាំ ១.៦០០ មុនគ្រិស្តសករាជ បើផ្ទុះគ្រូពៃតនិយាយថា ព្រះបាទបរិក្សិតទ្រង់មានព្រះជន្មរស់នៅក្នុងសម័យអថវ៌វេទទៅវិញទើបគួរ ព្រោះមហាភារតយុទ្ធកើតឡើងក្រោយអថវ៌វេទ ។ គម្ពីរបុរាណៈនេះ និយាយរឿងមហាភារតៈត្រឹមត្រូវទៅតាមគម្ពីរឫគ្វេទ ដែលមានមកតាំងពីបុរាណកាលម្ល៉េះ គឺគម្ពីរមហាភារតយុទ្ធនិងគម្ពីរបុរាណៈនេះគ្រាន់តែនិយាយបំពេញសេចក្ដីគម្ពីរវេទទៀតប៉ុណ្ណោះទេ ។ យើងបានដឹងថា ក្នុងសម័យអថវ៌វេទ តំបន់ពាយព្យនៃប្រទេសឥណ្ឌា មិនទាន់នៅក្នុងការគ្រប់គ្រងអាយ៌នសិនទេ ភាគខាងកើតនៃទំនាបមហាគង្គា ក៏ពួកអាយ៌នមិនទាន់ទៅដល់ដែរ ប៉ុន្តែមន្តគម្ពីរអថវ៌វេទ បានបង្ហាញការចលាចលប្រជាជនបរទេស

ទាំងអស់ គឺផ្លូវយមុនានេះទៅឲ្យដល់ទៅប្រទេសគន្ធារៈ និងប្រទេសពលិក (Bahlika) នៅភាគខាងលិច ដល់ទៅបាក់-ទ្រិយាន (Bactriane) ព្រមទាំងផ្លូវទៅប្រទេសមគធៈ (ពិហារខាងត្បូង) និងប្រទេសអង្គៈ (Bengale) ទៀតផង ។

មួយទៀត គេស្មានថាវប្បធម៌អារយ៉ន បានចូលទៅដល់ប្រទេសកោសលនិងវិទេហៈ ដែលនៅត្រង់ចន្លោះប្រទេសកុរុបញ្ចាល និងប្រទេសមគធៈអង្គៈហើយ ប៉ុន្តែសេចក្តីពិតក្នុងរវាង ១០០០ ឬ ៨០០ ឆ្នាំមុនគ្រិស្តសករាជ គឺក្នុងសម័យគតបថព្រាហ្មណៈទេ ទើបប្រទេសកោសលនិងវិទេហៈទៅជាអារយ៉នអស់ ដោយលោកមាឋវៈជាអ្នកវិទេហៈ បាននាំព្រះអគ្គទៅដល់ស្ទឹងសទានីរ (Sadanira) ជាព្រំប្រទល់ដែនដែលខ្ទនគ្រប់គ្រងក្នុងកាលនោះ សាសនាព្រាហ្មណ៍ ក៏បានចូលដល់ទីឋាននោះដែរ ។ ឯព្រះបាទជនក ជាព្រះរាជាមានព្រះនាមល្បីល្បាញនៃប្រទេសវិទេហៈ ហើយជាព្រះវរបិតានៃព្រះនាង

សិក្សាក្នុងរឿងរាមាយណៈនុ៎ះ បើថាជាព្រះរាជាវង្សដែលនេះមែន រឿងរាមាយណៈបានផុះផាលបរិបូណ៌ឡើងហើយ ក្នុងរវាង ១០០០ ឆ្នាំ មុនគ្រិស្តសករាជ ឬក៏ពីមុនកាលនោះទៅទៀត គឺក្នុងកាលនោះហើយ ដែលអរិយពលកាយ៉នបានចូលទៅដល់ទិសខាងកើតប្រទេសឥណ្ឌា បើយកគំនិតយល់ព្រមថា អរិយពលរាមាយណៈ បានចូលទៅដល់ភាគខាងត្បូងប្រទេសឥណ្ឌាដូចគ្នាដែរ ទើបសមហេតុផល ។

## ប្រទេសឥណ្ឌាទៅជាអាយ៌នក្នុងសម័យវេទ

គម្ពីរមន្ត ឬគម្ពីរមានវេទសាស្ត្រ ជាគម្ពីរមិនមានកាលបរិច្ឆេទពិតប្រាកដ ប៉ុន្តែគេយល់ថា កើតឡើងនៅខាងដើមគ្រិស្តសករាជ ។ គម្ពីរនេះ ជាច្បាប់ប្រសើរ គេទុកជាអក្សរសាស្ត្រសាសនាព្រាហ្មណ៍ពិសេសមួយ ដែលមនុស្សគោរពតែងឲ្យកើតឡើងបានមុនគ្រិស្តសករាជមិនយូរឆ្នាំប៉ុន្មាន ប្រែសេចក្តីថា

សម័យនេះហើយ ដែលអារ្យ័នយកប្រទេសឥណ្ឌាបាន ហើយ ឲ្យឈ្មោះប្រទេសនេះថា អារ្យាវ័ត៌ បានដល់ប្រទេសឥណ្ឌា ភាគខាងជើងដែលនៅចន្លោះសមុទ្រទាំងពីរ គឺខាងលិចមួយ ខាងកើតមួយ ភ្នំហេមវន្តនៅខាងជើង ភ្នំវិន្ធ្យានៅខាងត្បូង ទីឋាននៅចន្លោះព្រំប្រទល់ខាងជើងនិងខាងត្បូង ព្រមទាំងទី ចន្លោះទន្លេសរស្វតី គឺទន្លេស៊ុតិសត្វាថ៌ដែលនៅខាងកើត និងដៃទន្លេគង្គា និងយមុនានៅខាងលិច ។ ទីឋានទាំងអស់នេះ ហៅថា មធ្យមប្រទេស ។ មធ្យមប្រទេសនេះ គេចែកជា៦ភាគ ទៀត ភាគខាងលិចបំផុត ជាទីឋានប្រសើរ ហៅថា ព្រហ្មាវ័តៈ ។ ២ទីឋាននៅចន្លោះទន្លេសរស្វតីនិងស្ទឹងទ្ឫឞទ្វតី ដែល ជាដៃនៃទន្លេសរស្វតីភាគខាងកើតហៅថា ព្រហ្មឫទេស បាន ដល់ប្រទេសកុរុក្សេត្រ ប្រទេសមត្ស្យ ប្រទេសបញ្ចាល និង ប្រទេសសូរសេនៈ គឺតំបន់ទោ-អាប (Do-ab) សព្វថ្ងៃទាំង មូល ។ ដទៃពីនេះ ជាទីឋាននៃជនដែលមានការលាយឡំ.

ដោយវណ្ណៈអាស្រ័យនៅ ។ ឯព្រំប្រទល់ដែលគេកំណត់យកទិសខាងជើងនិងខាងត្បូងនេះ គឺគេកំណត់យកទៅតាមភូមិសាស្ត្រ ឯទិសខាងកើតនិងខាងលិច គេកំណត់យកទៅតាមសភាពប្រវត្តិសាស្ត្រក្នុងត្រិស្តសតវត្សទី ១១ ។ ភូមិភាគខាងលិចនៅក្នុងអំពលបរទេស ព្រោះមាននាយបរទេសត្រួតត្រា គឺពួកអាសេមេនីដ(១) (Achéménides) ភូមិភាគខាងកើត ជាដែនកើតពុទ្ធសាសនា និងសាសនាជេន ដែលជាសាសនាគូប្រឆាំងនឹងសាសនាព្រាហ្មណ៍ជាសាសនាអរ្យគ័រិយ ។

ប្រវត្តិក្រោយគម្ពីរវេទ– គម្ពីរមហាភារតៈនិងគម្ពីររាមាយណៈ ព្រមទាំងគម្ពីរបុរាណៈផង មានចុះបញ្ជីរាយកុលនាមព្រះរាជានិងនាមជនតាំងព្រេងនាយ ដែលមានមកតាំងពីបុរាណកាលដូចគម្ពីរវេទដែរ តែគម្ពីរវេទ មិនសូវមានចុះនាមព្រះរាជា

---

១–រាជវង្សពាស៊ី មានព្រះបាទ អាសេមេនីដ ជាដើមវង្ស ពីឆ្នាំ ៦៦៨ មកដល់ ៣៣០ មុន គ.ស. ។

ឬនាមផងច្រើនទេ ហេតុនេះមានច្រើនប្រការ គឺអត្ថបទត ៗ មកមានការប្រែប្រួល ឬ ផ្លាស់ប្តូរទៅតាមកាលវេលា ជួនកាលរឿងតាំងនោះកើតឡើងផ្សេងពីគម្ពីរវេទទៅទៀត ។ វប្បធម៌ឥណ្ឌាសម័យវេទពិត, មិនមែនសុទ្ធតែកើតចេញពីគម្ពីរវេទតាំងអស់ទេ ។ កន្លងការធ្វើប្រវេសឥណ្ឌាឲ្យទៅជាការយ៍ននេះមានវត្តមានជាប្រពៃណីផ្សេង ៗ កើតឡើង បន្តបន្ទាប់ជាន់គរលើគ្នាជាស្រទាប់លាយឡំគ្នា ច្រើនលើកច្រើនគ្រាណាស់ដោយប្រពៃណីរបស់អ្នកស្រុក ទីបំផុតក៏រលាយគ្នាទៅជាវប្ប-ធម៌ឥណ្ឌាសព្វថ្ងៃនេះមួយឡើង ។ លទ្ធផលនៃការលាយគ្នានេះ ក៏គឺរឿងមហាភារតយុទ្ធនិងគម្ពីរបុរាណៈនេះឯង ហេតុដូច្នេះហើយបានជាយើងឃើញមានការលាយឡំគ្នា ដូចជារឿងព្រះក្រិស្ណ ដែលមិនមានត្រាទុកក្នុងគម្ពីរវេទសោះ ទៅឃើញមាននៅក្នុងគម្ពីរតានោះឧបនិសទ ដែលជាគម្ពីរកើតជំនាន់ក្រោយទៅវិញ ។

ការកើតរាជវង្សពីសម័យបុរាណៈ — មាននិទាន ដំណាលទុកថា កាលពីព្រេងនាយ មនុស្សលើផែនដីនេះកើតមកពីទេវតា ហៅថា មនុ ។ "មនុ" នេះ ជំបូ[illegible]ថា ស្វយម្ភុវៈ (Svayambhuva) ប្រែថា " កើតដោយខ្លួនឯង " (ព្រះព្រហ្ម) គឺព្រះបាទ.វេនៈ (Vena) តែព្រះរាជាអង្គនេះ ល្បីព្រះនាមថា ជាអ្នកស្អប់ទ្រឹស្ដីដែលគេគោរព ពន់ពេកណាស់ ទើបគេព្រួ គក់បំបាត់ចោលទៅ ហើយលើកយកព្រះបាទបុថុ (Pṛthu) ដែលកើតមកពីការត្បូតព្រះហស្តទាំងពីរនៃសពនៃព្រះបាទវេនៈ ដូចជាគេត្បូតឈើអរណី ឲ្យកើតជាព្រះរាជាមួយអង្គទៀត ។ សេចក្ដីនេះ បញ្ជាក់ឲ្យឃើញច្បាស់ថា វង្សតមកសុទ្ធតែបាន ក្ដាប់ដោយពិធីយ៉ាងនេះ ដើម្បីរក្សាសន្តតិវង្សពីបុរាណទុកជា ប្រពៃណី ។ ព្រះបាទបុថុអង្គនេះ បានប្រសិទ្ធិឲ្យកើតផល សម្រាប់ចិញ្ចឹមមនុស្ស ហើយបង្កើតកាយ៍ធម៌ឲ្យកើតឡើង ។ ដូចព្រះបាទបុថុ កើតមកពីការត្បូតព្រះហស្តនៃព្រះបាទវេនៈ

ឯព្រះរាជាមួយអង្គទៀត ព្រះនាមព្រះបាទ និសាទ (Nisàda) ក៏កើតពីការពួតភ្លៅនៃសពនៃព្រះបាទវេនៈនេះដែរ តែព្រះរាជាអង្គនេះ មើលឆាយស្អប់ខ្ពើមខ្ពុំដែលគេគោរព ខ្លាំងពន់ពេកទៀត ហើយព្រះរាជាអង្គនេះ បានទៅកើតជាបុព្វបុរសនៃត្រកូលមិនបរិសុទ្ធមួយផ្សេងទៀត (រឿងនេះ គួរគិតថា មេសាសនាគ្រិស្ត ចេះរឿងនេះពិត ហើយក៏យកទៅប្រតិស្ឋារឿង អាដាំនិងអេវ (Adam et Ev) ជាបឋមមនុស្សក្នុងសាសនាគ្រិស្តទេដឹង ? ) ។ ព្រះបាទបុថុ ជាបឋមរាជាលើសគេលើលោក ជាចក្រពត្រាធិរាជ (Cakravartin) ដែលកើតឡើងដោយពិធីហៅថា "រាជសូយៈ" (Ràjasùya) គឺពិធីមហាយញ្ញៈដែលគេត្រូវធ្វើក្នុងកាលបុណ្យប្រាព្ធាភិសេកនៃព្រះរាជា ។

**ប្រពៃណីរាជវង្ស.**– ប្រពៃណីរាជវង្សតាមបុរាណនៃរាជសន្តតិវង្សមាន ២ ប្រការ មួយវង្សព្រះអាទិត្យ វង្សសូរ្យៈ ឬសូរ្យវង្ស (Suryavamça) មួយទៀតវង្សព្រះចន្ទ្រ វង្ស-

ព្រះសោម ឬ សោមវង្ស (Somavemça) ។

រាជវង្ស ១ សូរ្យវង្ស—ព្រះបាទ មនុវៃវស្វត (Manu-vaivasvata) ជាព្រះរាជបុត្រនៃទេវតាវិវស្វន្ត (Vivasvant) គឺព្រះអាទិត្យឬសូរ្យៈ ជាបុព្វបុរសដើមបង្អស់នៃសូរ្យវង្ស តមកដល់ព្រះបាទអិក្សាកុ និមិ សគរ អំសុមន្ត ភគីរថៈ តាំងអស់អង្គនេះ ទុកជាបាននាំទន្លេគង្គាឲ្យហូរពីឋានសួគ៌ មកកាន់ផែនពសុធាយើងនេះ ។ ឯព្រះបាទសុទាស (Sudâs) ដែលទុកជាជាមិត្រនឹងព្រះឥន្ទ ក៏គឺព្រះសុទាស ដែលបាន ត្រាទុកក្នុងគម្ពីរឫគ្វេទនេះឯង ។ ព្រះបាទរឃុ អជៈ ទសរថៈ ជាព្រះរាជានៃក្រុងអយោធ្យានៅដែនកោសល និងព្រះរាម ជាព្រះរាជបុត្រ ដែលជាវីរបុរសក្នុងរឿងរាមាយណៈ តាំងអស់អង្គនេះ សុទ្ធតែជាព្រះរាជសន្តតិវង្សសំខាន់ ៗ ត្រឹមតែ ៣ សតវត្សប៉ុណ្ណោះ ព្រះរាជសន្តតិវង្សកើតបាន ១១ តំណ តពីព្រះបាទសុទាសមក បើគួរថា ព្រះបាទសុទាសកើតរវាង

១៥០០ ឆ្នាំមុនគ្រិស្តសករាជ មុនឬក្រោយបន្តិច គឺយកតាមកំណត់កាលដែលតែងគម្ពីរវេទឡើង ដូច្នេះ ប្រហែលជាត្រូវគួរសមដល់ព្រឹត្តិការណ៍រឿងរាមាយណៈ គឺកាលដែលព្រះបាទជនកជាព្រះរាជានៃក្រុងវិទេហៈកើតឡើង ។

រាជវង្សសោមៈ ឬ សោមវង្ស— ផ្សេងពីសូរ្យវង្ស មានវង្សមួយទៀតហៅថា សោមវង្ស ដែលមានត្រកូលក្សត្រគ្រប់គ្រងនៅជាន់ក្រោយ ៗ ព្រះបាទសោមៈ ឬ ចន្ទ្រ (ចាស) ជាបុព្វបុរសដើមបំផុត ។ ព្រះបាទសោមៈអង្គនេះ ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គព្រះនាមពុធៈ Budha បាននាងព្រះនាងឥឡា ឬ ឥឌា ជាព្រះរាជធីតានៃព្រះមនុ វៃវស្វត ជាបុព្វបុរសខាងសូរ្យវង្ស ជាព្រះអគ្គមហេសី ។ ព្រះបាទពុធៈ និងព្រះនាង ឥឡានេះ មានព្រះរាជបុត្រមួយព្រះអង្គ ព្រះនាមបុរូរវៈ (Purûrava) ។ ព្រះបាទយយាតិ ជាតំណសន្តតិវង្សទី ៦ ។ ព្រះរាជាសោយរាជ្យតពីព្រះបាទយយាតិមក មិន

មែនព្រះរាជបុត្រច្បងដែលមានព្រះនាមថា យទុ (Yadu) ទេ គឺ ព្រះបាទ បុរុ (Puru) ជាព្រះរាជបុត្រពៅ ដែលជាព្រះអនុជ ទៅវិញ ព្រោះទ្រង់ជាទីគាប់ព្រះទ័យបិតាជាង ។ សន្តតិវង្ស ជាសាខាចេញពីព្រះបាទ យទុ ហៅ យាទវៈ (Yadava) កើតបានទៅជាព្រះរាជវង្សមួយទៀត មានកិត្តិសព្ទល្បីល្បាញ ផ្សេងពីសន្តតិវង្ស ពៅរវៈ (Paurava) ដែលជាកំណាវង្សមកពី ព្រះបាទបុរុ ។ បណ្ដាសន្តតិវង្ស ពៅរវៈ យើងគួរកត់ព្រះ នាមព្រះបាទទុស្មន្ត (Dusmanta) ជាព្រះរាជស្វាមីនៃព្រះនាង ឝកុន្តលា (Cakuntala) ។ ព្រះរាជបុត្រព្រះអង្គព្រះនាមភរត បានជាចក្រពត្រាធិរាជ (Cakravartin) ជាបឋម (ឯរឿងដែល និយាយថា ព្រះបាទបុរុជាចក្រពត្រាធិរាជដែរនោះ ជាប្រវត្ត-ណីផ្សេងមួយទៀត) តមកដល់ព្រះបាទកុរុ ដែលបានទៅជា កៅរវៈ ដល់ព្រះធ្ឫតរាស្ត្រនិងបាណ្ឌុ ដែលទៅជាបាណ្ឌវៈមាន ក្នុងរឿងមហាភារតៈ ។ សន្តតិវង្សជាសាខា ខាង យាទវៈ

(Yàdava) ព្រះកជាអង្គសំខាន់ៗ គឺ ព្រះបាទ អជុន កាត៌វីយ៍ (Kartavirya) ព្រះបាទវ៉ប្ហ៊ិណ (Yṛṣṇi) និងអន្ធក (Andhaka) ជាព្រះនាមនៃត្រកូលតាំងពីដើមប្រសើរ ឯព្រះក្ឫស្ណ កើតចេញពីត្រកូលវ៉ប្ហ៊ិណ ។

ព្រះកជាដែលមានព្រះនាមទាំងឈ្មោះ ហៅយកិតត្រាន់តែជានាមគង់រឿងព្រេងទេ ក្នុងគម្ពីរវេទ ក៏មាននាមព្រះកជាទាំងនេះដែរ ហើយគមក ព្រះនាមព្រះកជាទាំងនេះ បានក្លាយទៅជានាមមនុស្សឡើង ហើយគេរៀងទៅជាលំដាប់វង្សក្រោយអក្សរសាស្ត្រវេទ តាំងពីមុនគ្រិស្តសករាជប្រមាណជា ៣០០ ឆ្នាំ ។ នេះហើយជាដើមកំណើតសោមវង្ស ។

បើនិយាយទៅតាមគម្ពីរសាស្ត្រវិញ សោមវង្សនេះកើតនៅបច្ឆិមទេស: គឺនៅក្នុងក្សេត្រខាងជើងជាព្រហ្មាវេត: ។ គិតតាំងនេះហើយ ដែលកើតសោមវង្សមុនដំបូងឡើង សាខាសោមវង្សតមកទៀត បានដល់ព្រះកជា ដែលនៅប្រទេស

ផិតខាង ហើយមិនមែនត្រឹមតែប្រទេសកាសី (Kàçi) មគធៈ (Magadha) អង្គៈ (Anga) ដែលនៅខាងកើតប៉ុណ្ណឹងទេ វង្សនេះបានផ្សាយចូលទៅដល់ខាងត្បូងនិងចុងខាងត្បូងទៀតផង គឺរហូតទៅដល់ប្រទេសបាណ្ឌ្យៈ ដែលជាពូជពង្សចុះគេមកពីត្រកូលបាណ្ឌវៈ ។ តាមដំណើរនេះ យើងឃើញពិតជាវិក្ករ-កម្មនៃសោមវង្ស បានផ្សាយទៅធំទូលាយជាងខាងសូរ្យវង្ស ដែលមាននៅត្រឹមតែប្រទេសកោសលនិងវិទេហៈ ប៉ុណ្ណោះ ។ មួយទៀត យើងគួរសង្កេតមើលថា សោមវង្សបានផ្សាយទៅប្រទេសដែលកាន់សាសនាព្រាហ្មណ៍ដ៏សំខាន់ គឺមធ្យមទេស ដែនដីកុរុ បញ្ចាលដែលនៅក្រោមអំណាចដែនកោសលនិងវិទេហៈ ដែលជាវង្សផ្សេងគ្នា ។ ដូច្នេះ សភាពនយោ-បាយក៏ឃើញថាមានមតិពីរផ្សេងគ្នាដែរ មួយមានអំណាចនៅឥណ្ឌាត្រង់ដែនដីភាគខាងលើរវាងគង្គានិងយមុនា មួយទៀតមានអំណាចនៅឥណ្ឌាត្រង់ភាគខាងជើង គឺភាគកណ្ដាលទន្លេ

គន្ធា ៗ រឿងនេះ យើងបានឃើញក្នុងគម្ពីរបុរេត្តុមកថា ព្រះបាទសុតសោមច្បាំងតទល់ព្រះរាជា ១០ ព្រះអង្គ ហើយក្នុងគម្ពីរបុរាណៈ ជា ព្រះបាទសុតសោមអង្គនេះជាសូរ្យវង្ស បណ្តាព្រះរាជា ១០ អង្គនេះ ៨ អង្គជាសោមវង្ស សេចក្តីនេះបញ្ជាក់ថា វង្សទាំងពីរនេះ បានធ្វើសង្គ្រាមដណ្តើមវង្សគ្នាមកហើយ ៗ

---

# សិទ្ធរបស់ព្រាហ្មណ៍

ការសិក្សាសាសនាព្រាហ្មណ៍ ជាការលំបាកឥតគណនា ព្រោះសាសនាព្រាហ្មណ៍ ជាលទ្ធិចូលចិត្តបានដោយក្របំផុត សូម្បីព្រាហ្មណ៍ឯង ក៏ចូលចិត្តបានដោយលំបាកដែរ ។ ព្រាហ្មណ៍ដែលជាអ្នកប្រាជ្ញធំៗ បើនឹងអធិប្បាយពីសាសនារបស់ខ្លួន ក៏តែងតែលន់តួខ្លួនចុះញឹកៗជាមុនថា “រឿងនេះអធិប្បាយបានដោយលំបាកណាស់” ។ ការសរសេរលទ្ធិព្រាហ្មណ៍សម្រាប់សាមញ្ញជនទូទៅឲ្យចូលចិត្តងាយ ឲ្យស្គាល់បានងាយនេះ ជាការងារធ្ងន់បំផុតក្រៃលែង ។

សេចក្ដីលំបាកក្នុងការសិក្សាសាសនាព្រាហ្មណ៍កើតពីហេតុច្រើនប្រការគឺ:

ប្រការទី ១.- ផ្លូវសេចក្ដីនៃលទ្ធិនេះ ធ្វើឲ្យចូលចិត្តលំបាកក្នុងខ្លួនឯងស្រេចទៅហើយ គោលលទ្ធិព្រាហ្មណ៍សោត គឺជារឿងសុខុមគម្ភីរភាពពន់ពេកទៀត ជាការងារធំ

ក្រៅលែងជាន់ឯកដែលមនុស្សប្រុសណាបានធ្វើទុកមកដោយការ ប្រើគំនិតត្រិះរិះនិយមមោគតិយ៉ាងខ្លួនខ្លួន លំបាកយល់តាមតែ មនុស្សក្នុងបក្សពួកខ្លួនៗ ដំណើរការដោយងាយពុំបានឡើយ ។

ប្រភេទទី ២.- លទ្ធិសាសនាព្រាហ្មណ៍ផ្លាស់ប្តូរ ប្រែនជាប្រែនបែបបករ-ឧយត

អធិប្បាយ - [illegible] គឺលទ្ធិពួកអ្នកមានមុខ លទ្ធិពួកអ្នកដែលកើតជាតិដើមនៃឥណ្ឌា គឺទ្រាវិឌមួយ ។ ពួកអារ្យ័នដែលបានស្រុកចុះមកពីភាគខាងលើ មកជួបនឹង ពួកជនជាតិដើមឥណ្ឌា ដែលមិនមែនជាមនុស្សព្រៃផ្សៃ មាន វឌ្ឍនាការលឿនទៅមុនហើយ មានលទ្ធិសាសនាមកហើយ ដូចគ្នា ចំណេះវិជ្ជាដែលអន់ថយជាងអារ្យ័ននោះ គឺស្នាដៃ និងគ្រឿងប្រដាប់សម្រាប់ច្បាំងប៉ុណ្ណោះ ឯខាងលទ្ធិសាសនា បើទុកជាពួកអារ្យ័នមានអំណាច ក៏មិនអាចបង្គាប់ពួកជនអ្នក ដើម ឲ្យកាប់កាន់តាមលទ្ធិសាសនាខ្លួនដោយងាយបានដែរ

ត្រូវតែកែប្រែជំនឿទៀតតាំងសងខាងឲ្យចូលចុះគ្នាតែមួយ ដើម្បី
ស្រួលដល់ការគ្រប់គ្រងតទៅ ។

លើកទីពីរ.— ការប្រែប្រួលលទ្ធិអាយ៌ន និងលទ្ធិជនអ្នក
ដើមនេះ ជាហេតុនាំឲ្យកើតលទ្ធិ "វេទ" ឡើង មកដល់
ពេលនេះ លទ្ធិសាសនាណា ក៏បានចូលក្នុងសម័យថ្មីមួយ
ទៀតហៅថា "សម័យវេទ" ។

លើកទីបី.— ក្រោយមក កើតមានការបដិវត្តន៍ធំមួយគឺ ការ
សាងព្រះព្រហ្មឲ្យកើតឡើង ការបង្កើតព្រះព្រហ្មនេះធ្វើឲ្យកើត
លទ្ធិខ្ពង់ខ្ពស់ហើយរឹតតែជ្រៅជាងពីដើមថែមទៀត ដូចជាការ
កើតលទ្ធិ "អាត្មន" និងលទ្ធិ "ឧបនិបទ" ជាដើម ។
ដូច្នេះ រឿងវិចិត្រពិស្តារលទ្ធិសាសនាព្រាហ្មណ៍ ក៏រឹងរឹតតែ
កើតមានវិសេសវិសាលឡើងយ៉ាងក្រៃលែង ។

លើកទីបួន.— ព្រះពុទ្ធសាសនាកើតឡើង ក្នុងសម័យជា
មួយនឹងសាសនាធំមួយទៀត គឺសាសនាជេន ។ សាសនា

ជែននេះ មានព្រះមហាវីរៈជាអ្នកបង្កើត ជាគូដៃគ្នានឹងព្រះសម្ពុទ្ធជាម្ចាស់ ។ រីសាសនាទាំងពីរនេះ ស្ទើរមានគោលការបែកផ្សេងគ្នាច្រើនប្រការ ហើយជាគូប្រណាំងប្រជែងនៃគ្នានិងគ្នាក៏ដោយ តែមានវត្ថុបំណងមួយមុខត្រូវគ្នា គឺដើម្បីបដិវត្តន៍ជំនឿមនុស្សឲ្យចេញពីសាសនាព្រហ្មណ៍ នេះគឺជាហេតុឲ្យមេសាសនាព្រាហ្មណ៍ធំ ៗ ប្រមូលគ្នាក្ដាប់ខ្លួនក្រៃលែង ហើយប្រឹងប្រែងបញ្ចេញប្រាជ្ញា ដើម្បីសាសនាព្រាហ្មណ៍ ទីទាល់ទៅបាន ឬ ទីងមិតដើរចើកោលតទៅមុខបាន ក៏ត្រូវតែធ្វើបដិវត្តន៍ជំនឿក្នុងលទ្ធិសាសនាខ្លួនមួយត្រឡប់ទៅទៀត ហើយគេក៏បានរៀបចំកែខៃផ្លាស់ប្ដូរសាសនាព្រាហ្មណ៍ ឲ្យមានការប្រសើរវិសេសឡើង មានគោលអត្ថជ្រាលជ្រៅសុខុម តម្កើងការពារនិងតែងតាំងក្រៃលែងទៀត ម្ដងនេះទៀត គេឲ្យឈ្មោះលទ្ធិព្រាហ្មណ៍ថ្មីនេះថា លទ្ធិហិណ្ឌូ ។

ការផ្លាស់ប្ដូរច្រើនពេក ដល់ទៅ ៤ ជន លើជាក្រោម

ក្រោមជាលើ គ្រឡប់គ្រឡិនបាយបិណ្ឌជាបាយបាត្រយ៉ាងនេះ មើលជាការផ្លាស់ប្ដូរតិចៗ ក៏មិនជាការលំបាកអ្វីនឹងចូលចិត្ត ប៉ុន្មានដែរ យើងនឹងលើកសិក្សាការបរិវត្តន៍ ឬ ការផ្លាស់ប្ដូរពី បែបមួយទៅបែបមួយទៀតឲ្យទាល់តែចូលចិត្តងាយបាន តែ នេះ មិនដូច្នោះទេ ការផ្លាស់ប្ដូរគន្លងទំព្រាហ្មណ៍នោះ លោក ហូរ៉េស អា.រ៉ូស (Horace A.Rose) ដែលជាចាងហ្វាងក្រុមនរវិទ្យា (Anthropologle) របស់រដ្ឋាភិបាលឥណ្ឌា បានសរសេរទុក ថា "ផ្លាស់ប្ដូរទៅបកព្រេនលើកព្រេនដទៃណាស់តែគឺមិនឃើញ ជាមានផ្លាស់ប្ដូរត្រី ឃើញនៅតែដដែល" នេះបានជាលំបាក សែនលំបាក ដែលនឹងឲ្យដឹងថាអ្នកខ្លះផ្លាស់ប្ដូរ អ្នកខ្លះទៀតមិន ផ្លាស់ប្ដូរ ព្រោះការផ្លាស់ប្ដូរនោះ មើលទៅមិនឃើញច្បាស់ ផ្លាស់ប្ដូរព្រេនលើកទៅ គឺរឹតតែមានរឿងលើជាក្រោម ក្រោមជាលើ ទីបំផុតនៅតែដដែល អ្នកសិក្សានឹងបានឃើញ ហេតុការណ៍ទាំងនេះខ្លួនឯង ក្នុងកាលដែលសិក្សាតទៅ ។

ប្រការទី ៣.– រីឯកសារជាឡាក់ហាន ដែលគួរទុកជាគ្រឿងសំគាល់ការសិក្សាលទ្ធិសាសនាព្រាហ្មណ៍នោះ គឺជារឿងលំបាកសិក្សាដូចគ្នាដែរ ។ អ្នកប្រាជ្ញទាំងឡាយគេគន់ទុកថា លទ្ធិវេទ ឬ ត្រៃវេទ កើតមានមកមុនព្រះពុទ្ធសាសនាជាង ១.០០០ ឆ្នាំ អ្នកប្រាជ្ញខ្លះគេថា ២.៥០០ ឬ ២៥០០ ឆ្នាំ តែគម្ពីរវេទ ជាគម្ពីរបុរាណពិតមែន អ្នកប្រាជ្ញគ្រប់គ្នាក៏ទទួលស្គាល់ថាជា "គម្ពីរចាស់បរមបុរាណបំផុត" ។ រឿងនេះលោក ជែម ស. មេស្តុន (James S. Meston) បញ្ជាក់ថា គម្ពីរវេទនេះ គេទើបតែរួបរួមឲ្យបានជាឯកសារមួយពិតៗនោះ កាលពីគ្រិស្តសករាជ ១៦០០ នេះឯងទេ ។ ពាក្យនេះហើយមិនមាននរណាជឿទេ ព្រោះគម្ពីរវេទដែលគេប្រកាន់ថា ជាឯកសារ បុរាណបំផុត ហើយមកនិយាយថា ទើបតែនឹងរួបរួមជាគម្ពីរមួយបានពិតប្រាកដឡើងកាលពីគ្រិស្តសករាជ ១៦០០ ឆ្នាំនេះ ដូចជាមិនសមសោះ តែអ្នកនិពន្ធក៏ជាអ្នកប្រាជ្ញសិក្សា

វិជ្ជាឥណ្ឌា ម្នាក់ម្នាក់ខ្ពស់ជាងគេ ១ ធ្លាប់បានធ្វើជាចៅហ្វាយខេត្រ អង់គ្លេសប្រចាំនៅដែនផ្សេង ៗ នៃប្រទេសឥណ្ឌា អស់ យូរយារមកហើយ គឺមក លោកនេះបានជាបុគ្គលជាន់ខ្ពស់ ម្នាក់ហួតដល់បានជាតំណាងប្រទេសឥណ្ឌា ក្នុងប្រជុំសហ· ធនអង់គ្លេស (Commonwealth) ទៀតផង ហើយមកសរសេរ រឿងសំខាន់ដល់ជាតិនេះឲ្យភ្ញាក់ខ្លួនទៅម្តងទៀត តែបើយើង ល្បងពិចារណាមើល គឺឃើញបានជាសេចក្តីនៃអ្នកនិពន្ធដែល បញ្ជាក់ថា គម្ពីរវេទទើបតែនឹងបានរៀបរៀងជាគម្ពីរមួយពិតចំនួន ជា៧៦៧ឆ្នាំកន្លងមកនេះ ឃើញថាមិនខុសទេ ព្រោះរឿងសា· សនាព្រាហ្មណ៍មិនដូចជារឿងព្រះពុទ្ធសាសនាទេ ។ ពាក្យ ប្រៀនប្រដៅខាងពុទ្ធសាសនាគឺព្រះត្រៃបិដក លោកបានចារឹក ចុះជាតួអក្សរធ្វើជាគម្ពីរស្លឹករឹតយូរណាស់ជាង ២០០០ ឆ្នាំមក ហើយ ព្រះពុទ្ធសាសនាមានមេ មានគណៈសង្ឃដែលគេប ត្រង់តមក មានរបៀបវិន័យចងរឹតឲ្យមាំជាមួយគ្នា ពុទ្ធ

មានការផ្ទៀងផ្ទាត់ពិនិត្យពិច័យហៅថា សង្គាយនា ហើយតមក មិនយូរប៉ុន្មាន ក៏ចារឹកជាតួអក្សរ រៀបចំទុកជាគម្ពីរបរិបូណ៌ មិនមានឥតណា ទំនងជាសំបូរកើតទៅទៀតបានឡើយ ៗ គម្ពីរពុទ្ធសាសនា យើងការបកស្រាយមកប្រែជាសេចក្តីសំរាយហើយផ្សាយទៅ ការធ្វើដូច្នេះ យើងប្រកាន់ថាជាការកុសលផង ព្រោះផលមានរឿងនិយាយថា សរសេរចារបង្គូរអក្សរ គម្ពីរព្រះត្រៃបិដកអោយបេក្ខ បានកាន់សង្ឃសើមដ៏បានសាងព្រះពុទ្ធរូបមួយអង្គ ៗ ឯសាសនាព្រាហ្មណ៍មិនដូច្នោះទេ គម្ពីរវេទ ដើម្បីការចំនួនិយាយថា គេបានចារឹកជាតួអក្សរមកយូរណាស់ហើយ ជាឯកសារបុរាណ មានអាយុច្រើនឆ្នាំណាស់មកហើយ ក៏ពិតមែន តែមិនមានការសង្គាយនា មិនមានការពិនិត្យត្រួតត្រាមើល ហើយក៏បង់គង់ទីប្រជុំថា ជាគម្ពីរកណ្តាលជាស្ថាពរឡើយ ៗ ឯគម្ពីរដែលគួរប្រកាន់ទុកថាជារបស់កណ្តាល ដូចគម្ពីរព្រះត្រៃបិដក

យើងនេះមិនមានទេសោះ  គម្ពីរវេទជាគម្ពីរសម្បត្តិដោយចំពោះ
របស់ព្រាហ្មណ៍ ហើយគេប្រគល់ឲ្យត្រកូលរបស់ខ្លួនគេរក្សាជា
មត៌កខ្លួនតគមក ឬគេឲ្យដល់អ្នកកំណាន់ខ្សែវង្សរបស់គេ ដែល
មានគតិពុកក្នុងការប្រកបពិធីកម្មដែលទាក់ទេសលាក់លៀមបិទបាំង
មិនឲ្យអ្នកណាដឹងទៀតផង មិនតែមិនគេរៀន ដកស្រង់ ឬចម្លង
គម្ពីរវេទមកដើម្បីនឹងផ្សាយជាបណ្ណាក្នុងសាលប្រជាជនយើងទៀតក្នុង
ព្រះពុទ្ធសាសនា នោះឥតអ្វីមានទេ សេចក្តីនេះក្នុងយើងស្រួលៗ
គឺបើនរណាអាចហាមឃាត់ឬដកស្រង់គម្ពីរស័ក្តិសិទ្ធិនោះ គេទុក
ជាមនុស្សខុសឆ្គង ឬជាមនុស្សគាក្រក់មានទោសបញ្ចូនទៅក្រៅលែងៗ
កាលបើគម្ពីរវេទមិនមែនជារបស់កណ្តាល ត្រាន់តែជារបស់
ផ្ទាល់ខ្លួនរបស់បុគ្គលដូច្នេះ បើនឹងត្រូវគត់ត្រាចម្លង ក៏ចាំបាច់តែ
អ្នកម្ចាស់របស់អនុញ្ញាតឲ្យរៀបបាន តែតាមការពិត ម្ចាស់របស់
តែងតែព្រាថ្នាចង់រក្សាទុក រក្សាលិខិតសិទ្ធិទុក សម្រាប់ជាកេរ្តិ៍
មត៌កខ្លួនឲ្យតែផងដែលគួរជារបស់ខ្លួនគេនៅតែប៉ុណ្ណោះ ៖ មិន

ព្រមឲ្យគេ ឬលោកទុកបិនព្រមឲ្យគេដៃធំដឹងគួរឡើយ ។

សាសនាព្រាហ្មណ៍ មិនមានបេសាសនាជាមនុស្ស ដូច ព្រះពុទ្ធសាសនា ទេសាសនាព្រាហ្មណ៍មិន[illegible]មានជាមនុស្សទេ តែងមានស្ថិតនៅលោកនេះ ការឃុំគ្រងទុកជាកំណត់ប្រពៃ ដើម្បីរក្សាការទៀងទាត់ ការពិតឲ្យបានជាក់លាក់របស់លទ្ធិនេះ មិនមានវិធីដ៏ធ្វើបាន ដូចពុទ្ធសាសនាឡើយ ។ ព្រាហ្មណ៍បាន រៀបក្បួន[illegible] ជាដើមរបស់លទ្ធិខ្លួន[illegible] តែមិនមានអ្នកណា ការពារក្បួនរបស់ទាំងនេះទុកគង់ ហើយប្រពៃបានឡើយ ទោះគេ តែមិនទោះក្បួន ដែលទាំងមិនមានអ្នកណាសម្រេចសេចក្តីដាច់ខាតទៀតផង ។ ដូចនេះរឿងផ្សេង ៗ ដែលខ្វែងគ្នា ក៏នោះតែខ្វែងគ្នាទៅ ដូចគម្ពីរខ្លះនិយាយថា ទេពតាចក្រៈជាកូនរបស់ព្រះទេពអទិតិ គម្ពីរមួយទៀតនិយាយថា ព្រះទេពអទិតិ ជាកូនទេពតាចក្រៈវិញទេ យ៉ាងនេះជាដើម ។ រឿងបែបនេះ ឥតមានអ្នកណាការកាត់សេចក្តីឲ្យដាច់ខាតបានទេ

ហើយក៏បណ្ដោយឲ្យនៅតែមានសេចក្ដីខ្វែងគំនិតស្ទើរតែរាល់ៗ ដូចនិយាយនេះរហូតមក ។ ឯខាងពុទ្ធសាសនាវិញ មិនដូច្នោះទៀយ បើប្រសិនជាមានសេចក្ដីខ្វែងគំនិតត្រង់ណាមួយ តែងតែមានការវិនិច្ឆ័យក្នុងប្រជុំដែលហៅថា សង្គាយនាមិនខាន បានជាព្រះពុទ្ធវចនៈមានការទៀងទាត់រហូតមក

ឯការប្រែប្រួលគម្ពីរវេទដែលនិយាយថា កើតពី ៧០៧ ឆ្នាំ គ្រិស្ដសករាជ ហើយបានជាគម្ពីរមួយនោះ ទោះជាដូចម្ដេចក្ដីក៏ទុកជាជា "សង្គាយនា" ទៅចុះ តែការមកសង្គាយនាក្នុងកាលជាខាងក្រោយយូរពេកដូច្នេះ តែងមានការអត្ថកយច្រើនណាស់ ព្រោះសង្គាយនា ក្នុងកាលដែលសាសនានេះវិបត្តិវិបរិតប្រែប្រួលផ្លាស់ប្ដូរច្រើនដង ច្រើនគ្រាទៅហើយ មិនឲ្យមានការទៀងទាត់ តាមគោលដើមម្ដេចបាន ដូចជារឿងដែលយើងបានដឹងក្នុងគម្ពីរវេទ គឺទេពតាអគ្គិវៈថា ព្រះវិស្ណុមានឡាក់ឋាន ក្នុងទីដទៃ ៗ ប្រាប់ច្បាស់ថាជាទេពតាកើត

ក្នុងកាលក្រោយទៀត គឺទើបតែនឹងកើតឡើងក្នុងសម័យសាសនាព្រាហ្មណ៍ផ្លាស់រូបទៅជាសាសនាហិណ្ឌូនោះហើយទេ ម្តេចឡើយក៏ប្រែទៅជាមានឈ្មោះនៅក្នុងគម្ពីរវេទដែរ ហើយថាមានឋានៈទាបជាងព្រះឥន្ទ្រ។ សេចក្តីពិតក្នុងគម្ពីរវេទមានសេចក្តីប្រាកដច្បាស់លាស់ថា "ព្រះវិស្ណុមានឋានៈទាបជាងព្រះឥន្ទ្រ" ពិតមែន ។ តែហេតុដូចម្តេចក៏បានជាមាននាមព្រះវិស្ណុទៅនៅក្នុងគម្ពីរវេទ? គឺពួកព្រាហ្មណ៍អ្នកនោះតាក់តែងគម្ពីរវេទជាលទ្ធិចាស់ នៅប្រកាន់ថា "ព្រះឥន្ទ្រជាទេវតាខ្ពស់ផុត" នៅឡើយ ហើយមកដល់សម័យហិណ្ឌូ ក្នុងសម័យដែលប្រែរូបគម្ពីរវេទ ហើយចារជាក្បួនក្បាលឲ្យបានជាគម្ពីរមួយពិតប្រាកដឡើង ពីកាលនោះ ពួកព្រាហ្មណ៍ដែលនៅតាក់តែងគម្ពីរវេទជាន់ចាស់ ក៏លបលួចយកឈ្មោះព្រះវិស្ណុ ដែលជាទេវតាខ្ពស់ផុតរបស់លទ្ធិហិណ្ឌូ ទៅសរសេរដាក់បន្ថែមក្នុងគម្ពីរវេទឡើង ជាការក្លែងបន្លំឲ្យគេយល់ថា "ព្រះវិស្ណុមានឋានៈទាបជាង

ព្រះឥន្ទ" ដើម្បីនឹងបន្ថោកបន្ទាបព្រះវិស្ណុ ។ ហេតុដូច្នេះកាលមកនេះ នាមព្រះវិស្ណុក៏កើតប្រាកដឡើងក្នុងគម្ពីរវេទ ហើយជាប់រហូតមកដល់បច្ចុប្បន្នកាលនេះឯង ។

សេចក្ដីទាំងលើដូចបាននិយាយមកនេះហើយ ធ្វើឲ្យវិលវល់កើតជាការត្រឡប់ត្រឡិន ក្រោយជាលើ លើជាក្រោយច្រើនសែនក្រៃលែង ។ ចំណែកៈទេវតាផ្សេងៗទៀត យើងមិនអាចនឹងនិយាយបញ្ជាក់ឲ្យពិតប្រាកដបានទេ ដូចជាជាទេវតាដើមរបស់អ.យ៉ិននោះ តើមានប៉ុន្មានអង្គ? ទេវតារបស់ជនជាតិដើមឥណ្ឌានោះតើមានប៉ុន្មានអង្គឲ្យប្រាកដ? ការផ្សំផ្សំគ្នាតើដូចម្ដេចខ្លះ? សម័យកសាងព្រះព្រហ្មទៀត បានទេវតាអង្គណាខ្លះកើតឡើងថ្មីទៀត? សម័យហិណ្ឌូកើតឡើងមានទេវតាថ្មីកើតទៀតប៉ុន្មាន? រឿងទាំងនេះ យើងមិនអាចនឹងធ្វើបញ្ជាក់ឈ្មោះឲ្យបានពិតប្រាកដទេ បើមិនធ្វើបានខ្លះក៏បានត្រឹមតែការពិចារណាហេតុផលជុំវិញប៉ុណ្ណោះ ដូចជាអ្នក

ប្រាជ្ញអល្លឹម៉ីនត៍ម្នាក់ធ្វើការពិចារណាគម្ពីរវេទ គឺសង្កេតមើលពាក្យពេចន៍ក្នុងគម្ពីរវេទនោះឯង បើទេវតាអង្គណាដែលគម្ពីរវេទថាកើតមុនគេ មានការនិយាយយ៉ាងច្បាស់លាស់ មានរឿងរ៉ាវច្រើន មានបទសូត្រស្តុតិច្រើនជាងគេទុះ គំល្មមនឹងជឿបានថា ជាទេវតាសម័យវេទពិតៗ បើទេវតាអង្គណាដែលមាននិយាយគ្រាន់តែខានមិនបាន ហើយមាននាមជាក់ទានក្រោយៗ គេផង នេះគឺគួរចូលចិត្តថា ទេវតាអង្គនោះៗគេទើបនឹងបន្ថែមក្រោយទៀតទេ គឺជាទេវតាកើតឡើងជំនាន់ក្រោយៗ ។ វិធីមួយទៀត ពួកអ្នកប្រាជ្ញជាអ្នករិះរកក្នុងសម័យថ្មី ប្រើសម្រាប់ពិចារណារឿងទេវតាព្រាហ្មណ៍នោះគឺ “វិធី ម៉ែឪកើតក្រោយកូន” ព្រោះទេវតាជាអ្នកសាងលោកដ៏ធំក្រៃលែងនោះតែងតែកើតឡើងខាងក្រោយអ្នកដែលខ្លួនសាង ៗ ឯលក្ខណៈដែលនាំឲ្យកើតទេវតាក្នុងសាសនាព្រាហ្មណ៍ឡើងនោះ ដើមឡើយ កើតពីការគោរពបូជាទេវតា

មួយអង្គៗ ចំពោះខ្លួន ដោយជឿការសក្តិសិទ្ធិចំពោះខ្លួន គេមិនបានគិតជាប្រស្នាសួរថា ទេវតានេះកើតមកពីណា ឬជាកូនអ្នកណាដូច្នេះទេ ក្នុងកាលតមក កាលមនុស្សមានការបេះដឹង ការបេះដឹងរបស់មនុស្សចំរើនឡើងហើយ ទើបមនុស្សចូលចិត្តគិត ចូលចិត្តសង្ស័យ ហើយគេតាំងប្រស្នាសួរគ្នាថា ទេវតាអង្គនេះអង្គនោះកើតមកពីណា? ជាកូនចៅលោកណា? សេចក្តីពិត ម្ចាស់លទ្ធិនេះឯង ជាអ្នកនាំកសាងប៉ៃសាងថ្មីឡើង ដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន ៗ ហេតុនេះហើយ បានជានាំឲ្យកើតទៅជាទេវតាអង្គនេះ អង្គនោះ មានឪមានម៉ែ មានយាយមានតា ដែលកើតមានមុនរាប់ពាន់ឆ្នាំមកហើយ ៗ

ហេតុផលដូចជាបានពោលមកខាងដើមនេះ ធ្វើឲ្យយើងឃើញបានថា ការសិក្សាលទ្ធិព្រាហ្មណ៍របស់ព្រាហ្មណ៍នោះ បើនឹងសិក្សាជាវិជ្ជាពិតៗ ដើម្បីបេះដឹង មានការលំបាកមិនតិចទេ តែបើសិក្សាដោយមិនត្រូវការឲ្យបេះដឹងពិតប្រាកដទេ

អ្នកណានិយាយថា ដូចម្ដេច ក៏ចេះតែរើសយកមករក្សាទៅ ហើយប្រព្រឹត្តទៅ ព្រោះជាមានសេចក្តីខ្វែងគ្នាដូចម្ដេច ក៏កុំ ជាអ៊ីស៊ីចេះតែស្ងៀមទៅ ធ្វើត្រឹមមាន ល្មមនឹងធ្វើទៅបាន តែនឹង យកឲ្យជាសាច់ការជាក់លាក់ពិតមែន ដូចការសិក្សាក្នុងសាសនានោះ គេមិនអាចនឹងធ្វើក្នុងសាសនាព្រាហ្មណ៍ បានឡើយ ។

តែទោះយ៉ាងណាក្តី លទ្ធិសាសនាព្រាហ្មណ៍នេះ ជារឿងសុខុមគម្ពីរភាពក្រៃលែង ជាលទ្ធិសាសនាដែលមាន ការសំខាន់បំផុត ហើយគេបានបណ្ដុះឲ្យចាក់ឫសគល់ចុះទៅ ជ្រៅយ៉ាងណាស់ ក៏កើតទៅជាការគាប់អាន របស់ជនជាតិ ឥណ្ឌាគាត់ច្រើន ព្រោះជាមានក្នុងសាសនានិងសាសនាដទៃ សាសនាឥស្លាម ចូលមករុករានជាន់ក្រោយក៏ដោយ លទ្ធិ សាសនាព្រាហ្មណ៍ ក៏នៅតែមាំមួនក្នុងប្រទេសឥណ្ឌា ដូចជា ការមាំមួននៃកំពែងហិមាល័យដូច្នេះឯង ៈ សភាពមាំមួនទាំង នេះ រឹតតែមានច្រើនឡើងៗ កាលដែលលទ្ធិព្រាហ្មណ៍

បានក្លាយទៅជាលទ្ធិហិណ្ឌូទៅហើយ ។ តាមតួលេខជំរឿនប្រជាជនរបស់ឥណ្ឌាក្នុងឆ្នាំ ១៩៣១ គេបានតួលេខចំនួនអ្នកកាន់សាសនានាំ ៗ ក្នុងឥណ្ឌាដូចតទៅនេះ ៖

១– ហិណ្ឌូ . . . . . ២៣៨.៦៤៤.១៨៧ នាក់

២– ឥស្លាម . . . . . ០៧៧.០៩២.៧០៦ នាក់

៣– ភូតបូជាវេចលនិយម . ០០៧.៦២៩.៩៥៩ នាក់

៤– គ្រិស្ត . . . . . ០០៥.៩៦៥.៦៥៧ នាក់

៥– ស៊ីក្ស . . . . . ០០៤.៣២៤.៨៦៤ នាក់

៦ ជេន . . . . . ០០១.២៥១.៣៨៤ នាក់

៧– ពុទ្ធ . . . . . ១០០.៤៣៨.៧១៩ នាក់

៨– បាស៊ី . . . . . ០០០.១០៩.៣៣៣ នាក់

៩– លទ្ធិផ្សេងៗ . . . ០០០.៤៤៥.២០៥ នាក់ៗ

មើលចុះ ! ជឿថាមិនមានបុគ្គលណាលទ្ធិណាក្នុងលោកនឹងអាចទៅទំលាយលាងបង់ ឬ ក៏គ្រាន់តែធ្វើឲ្យសាបរលាប

ទន់ខ្សោយសាសនាព្រាហ្មណ៍ក្នុងឥណ្ឌាបានឡើយ ។ ដោយពី ប្រទេសឥណ្ឌា ផែនដ៏ធេង ។ ដែលពុទ្ធសាសនាបានផ្សាយ ចូលទៅដល់ដូចប្រទេស ឥណ្ឌូណេស៊ី ភូមា ខ្មែរ សៀម លាវ លទ្ធិសាសនាព្រាហ្មណ៍ក៏ចូលលាយឡំជាមួយផងដែរ ។

មួយទៀតសេចក្ដីលំបាកក្នុងការសិក្សាសាសនាព្រាហ្មណ៍ នេះ ចាប់ផ្ដើមលំបាកតាំងពីដើមទីតែម្ដងទៅ គឺលំបាកកំណត់ ពីរឿងបែងយុគបែងសម័យក្នុងសាសនាព្រាហ្មណ៍ នេះឯងជា ដើមទៅ ជាប្រស្នាលំបាកបំផុតលំបាកជាងគេការសិក្សាសាសនា ព្រាហ្មណ៍នោះ គួរមិនបែងយុគបែងសម័យដូចម្ដេចទៅហ្ន៎ ?

សាស្ត្រាចារ្យរាធាក្រិស្ណន (Rabhakṛsnan) ជាសាស្ត្រាចារ្យ ទស្សនវិជ្ជា ក្នុងបច្ចុប្បន្ននេះ ហើយក៏ជាប្រធានាធិបតី នៃប្រទេសឥណ្ឌាផង បានបែងចែក តែមិនមែនបែងចែក សាសនាដោយត្រង់ទេ គ្រាន់តែបែងចែកសម័យទស្សនវិជ្ជា របស់ប្រទេសឥណ្ឌាប៉ុណ្ណោះ លោកបែងចែកជា ៣ សម័យគឺ

១– សម័យទីមួយ– គឺសម័យវេទ (A. Vedic period, F. Période vedique) ឲ្យវេលាតាំងពី ១.០០០ ឆ្នាំ មកដល់ ១០០ ឆ្នាំមុនពុទ្ធកាល ។

២– សម័យទីពីរ– គឺសម័យកាព្យ ឬ កាព្យ (A. Epic Period, F. Période épique) តែសាស្ត្រាចារ្យ ភាគច្រើន ប្រើសេចក្ដីសំគាល់ដល់សម័យដែលពុទ្ធសាសនា និងសាសនាជេនកំពុងរុងរឿងជាគូនឹងសាសនាព្រាហ្មណ៍ ឲ្យវេលាតាំងពី ១០០ ឆ្នាំ មុនពុទ្ធកាល មកដល់ប្រមាណជា ព.ស. ៧០០ ឆ្នាំ ។

៣– សម័យទីបី– គឺសម័យ ទស្សនៈ (A. Period of six systems, F. Période des six systemes) ត្រូវគ្នានឹងសម័យឥណ្ឌូ ឲ្យវេលាតាំងពីប្រមាណជា ព.ស. ៧០០ តមក ។

លោកហូរ៉ាស អា.រ៉ូស (Horace A. Rose) បានហៅក្រុមមនុស្សវិទ្យាថែនឥណ្ឌា ដែលពោលនាមលោកមក

ហើយខាងដើម បានចែកជា ៣ សម័យដូចគ្នាគឺ:

១- សម័យទីមួយ - គឺសម័យវេទ ដូចលោកភគកុម្ពុន ។

២- សម័យទីពីរ - សម័យកាវ្យ ឬ កាព្យ ដូចលោកភគកុម្ពុន តែអធិប្បាយទុកជា សម័យអក្សរសាស្ត្រធំៗ របស់ឥណ្ឌា គឺមហាភារតៈ និងរាមាយណៈ (រាមកេរ្តិ៍) ។

៣- សម័យទីបី - សម័យឧបនិបឺទ ក្រែងសម័យហិណ្ឌូ ។

អ្នកប្រាជ្ញវិទេសជាជនជាតិអល្លឺម៉ង់ម្នាក់ឈ្មោះសាស្ត្រាចារ្យ កាលើ ក្លេម៉ង់ (Carl Clemen) នៃមហាវិទ្យាល័យក្រុងបោន (Bonn) ដែលរួមជាមួយអ្នកប្រាជ្ញច្រើននាក់ បានបែងចែកជា ៣ សម័យដែរ គឺ:

១- សម័យទីមួយ - គឺសម័យវេទ ដូចអ្នកប្រាជ្ញទៃ ១ ដែលយើងបានពោលឈ្មោះមកហើយដែរ ។

២ - សម័យទីពីរ គឺសម័យព្រាហ្មណៈ ចាប់ផ្ដើមតាំងតែពីវេលា ដែលព្រាហ្មណ៍បានសាងព្រះព្រហ្មឡើង ។

៣ សម័យទីបី- គឺសម័យហិណ្ឌូ ។

ឯកាលបរិច្ឆេទវេទ បណ្ឌិតអ្នកប្រាជ្ញវេទគ្រប់ប្រជ្ញាន មិនយល់ស្របគ្នាទេ ។ រឿងនេះមានការលំបាកកំណត់មែន ។ យើងសូមលើកយកអ្នកប្រាជ្ញទាំងឡាយ ពីព្រោះកាលបរិច្ឆេទវេទផ្សេងៗគ្នានេះ : លោកយ៉ាកោប៊ី (Jocobi) និយាយតាមតារាសាស្ត្រថា វេទកើតឡើងក្នុងឆ្នាំ ៤.៥០០-២.៥០០ មុនគ្រិស្តសករាជ ។ លោកកោលប្រ៊ុក (Cole Brooke) និយាយតាមវិជ្ជាជោតិស ថា គម្ពីរវេទចាប់តែងឡើង ក្នុងគ្រិស្តសត-វត្សទី ១៤ នេះទេ ។ ឯលោកម៉ាក់ មូល្លើ (Mox Muiller) ជាអ្នកប្រាជ្ញវេទម្នាក់ បានសិក្សាវេទដ៏ពេញនិយាយថា បើយកគម្ពីរឧបនិស័ទមកជាគោលដើម ដើម្បីនឹងរកកាលបរិច្ឆេទត្រូវកំណត់ថា គម្ពីរឧបនិស័ទកើតមុនព្រះសមណគោតម គឺ

ប្រមាណជា ៥០០ ឆ្នាំមុនគ្រិស្តសករាជ ដូច្នេះ គម្ពីរវេទត្រូវតែងឡើងរវាងឆ្នាំ ១.២០០–១.០០០ ឆ្នាំមុនគ្រិស្តសករាជ តែគេអាចគិតកើនលើសជាងនេះទៀតគឺ ១.០០០, ១.៥០០, ២.០០០ ឬ ៣.០០០ ឆ្នាំមុនគ្រិស្តសករាជ ។ លោកវិនធើនិត្ស (Winternitz) ជាអ្នកប្រាជ្ញវេទវិសេសម្នាក់ដែរ លោកថា វេទតែងឡើងរវាង ១.២០០–១.០០០ ឆ្នាំមុនគ្រិស្តសករាជ លោកនិយាយបន្ថែមទៀតថា វេទគេតែងបន្ត ៗ គ្នាមក ចាប់ផ្ដើមតាំងពីអតីតកាលដែលគេមិនបានដឹង មកដល់ត្រឹម ៥០០ ឆ្នាំមុនគ្រិស្តសករាជ គឺពី ១.២០០–៥០០, ១.៥០០–៥០០, ២.០០០–៥០០ ឡើងទៅ ឬ បើគិតតាមការគេឃើញថ្មី ៗ នេះ ៨០០–៥០០ ឆ្នាំ មុនគ្រិស្តសករាជ ។ អ្នកប្រាជ្ញឥណ្ឌាខ្លះបាននិយាយថា វេទនេះ កើតឡើងកាលពី ៣.០០០ មុនគ្រិស្ត ។ កាលពីគ្រិស្តសតវត្សរ៍ ទី ១៩ លោកទីឡាក់ (Tilak) បានកំណត់ទុកថា វេទនេះកើតឡើង ៦.០០០

មុនគ្រិស្តសករាជ តែមានអ្នកប្រាជ្ញឥណ្ឌាខ្លះទៀតគេក៏ថា មិនមែនទេ មុនសករាជនេះទៅទៀត ។ បើតាមប្រពៃណីហិណ្ឌូ គេនិយាយថា លោក "វ្យាសៈ" ជាអ្នកតែងគម្ពីរឫគ្វេទ លោកតែងក្នុងខាងដើមកលិយុគ គឺប្រមាណជា ៣.០០០ ឆ្នាំមុនគ្រិស្តសករាជ ។

ការបែងចែកសម័យវេទរបស់អ្នកប្រាជ្ញទាំងឡាយ ដែលបានពោលអាងរួចមកខាងលើនេះ ជាការបែងចែក... វិធីរៀងខ្លួនម្យ៉ាងម្នាក់ បើយើងលើកយកគំនិតទាំងបីខាងលើនេះមកពិចារណា ដើម្បីរកវិធីងាយសិក្សាលទ្ធិព្រាហ្មណ៍នោះ យើងគួរបែងចែកទៅជា ៤ សម័យវិញដូចតទៅនេះ :

១– សម័យអាយ៉ន:

២– សម័យវេទ

៣– សម័យព្រាហ្មណៈ

៤– សម័យហិណ្ឌូ

ការបែងចែកនេះ មានការជួយខុសពីគំនិតអ្នកប្រាជ្ញទាំងឡាយ ដែលលោកបានបែងចែកមកហើយ តែងាយស្រួលដល់ការសិក្សានៅប្រទេសយើង ។

ដើមឡើយ មនុស្សយើងមិនមានការចេះដឹង មិនយល់សភាពធម្មជាតិ ទឹក ដី ភ្លើង ខ្យល់ នេះជាដូចម្តេច ដឹងត្រឹមតែថា ផែនដីកក្រើក ផ្គរបន្ទោរក្តិកក្តក នៅលើអាកាសវេហាស៍ ហើយគម្រាមជូនជាន ក៏សំគាល់ថា នេះជាទេពតាខ្មោចបិសាច ឬអ្នកតាណាមួយ ព្រោះហើយក៏ភ័យខ្លាច ប្រកាន់យកវត្ថុទាំងនោះមកទុកជាសរណៈ ជាទីពឹងរបស់ខ្លួន ហើយបបួលគ្នាទៅបន់ស្រន់ស្រែកបួងសួង សុំឲ្យបានសេចក្តីសុខ ការប្រកាន់យកធម្មជាតិ ទឹក ដី ភ្លើង ខ្យល់ នេះទុកជាសរណៈ ហៅថាជីវចលនិយម (Animisme) បានជាព្រះសម្ពុទ្ធត្រាស់ទុកថា :

ពហុំ វេ សរណំ យន្តិ បព្វតានិ វនានិ ច

អាភាបរុក្ខាទេវតាធំ មនុស្ស ក្រុយគង្គិតា ។

មនុស្សព្រេនណាស់រ៉ុយ ដែលមានភ័យមកគម្រាមហើយ តែងតាំងយកក្ដុំក្រុំថ្ម ព្រៃ ភ្នំ ដើមឈើ ទេវី មកទុកជាទីពឹងរបស់ខ្លួន ។

x

១- សម័យអាយ៉ង_ សម័យនេះ ការវិវត្តន៍ផ្លូវចិត្ត នៃមនុស្សលោកបានផ្ដើមចម្រើនហើយ មនុស្សមិនសុខចិត្ត ព្រមចាញ់ធម្មជាតិទេ ខំប្រឹងប្រែងស្វែងរកការចេះដឹង រក- សេចក្ដីពិតគង់តែតាំងឡាយ ហើយក្នុងសម័យនេះ កើតគម្ពីរវេទឡើង ។ ពួកជនដែលមានការចេះដឹងនេះហើយ ដែលយើងហៅថា អាយ៉ង ។ ពាក្យថាអាយ៉ង គេសរសេរ

ផ្សេងៗគ្នា ខ្លះសរសេរជា អារ្យ័ន ខ្លះសរសេរជា អារិ-
យ័ន ឬ អរ្យ័ន ឬ ក៏ អារ្យ៉ន (A.Aryan, F. Aryas ou Aryen) ។
ប្រវត្តិសាស្ត្រពោលទុកថា អារ្យ័នជាបុព្វបុរសនៃគ្រួសារធំមួយ
ហៅថា ឥណ្ឌូ-អឺរ៉ុប ឬ ឥណ្ឌូ-អារ្យ៉ន មានជាតិភូមិនៅ
ឧសុស (Oxus) ក្នុងភូមិភាគកោកាស (Caucase) និងខ្ពង់
រាបនៃប៉ាមីរ (Pamir) ដែលគេទុកជាដំបូលពិភពលោក
នៅតាមឆ្នេរសមុទ្រកាស្ពីយែន (Mer Caspienne) និងឆ្នេរ
សមុទ្រអារ៉ាល់ (Aral) ។ ខ្មែរយើងហៅទីនេះថា ផ្ចិតផែនដី ។
ភូមិភាគតំបន់នេះ ជាទោលិកា គឺជាអន្លើជាលំនៅឋាន
នៃសាខាមួយធំនៃមនុស្សពួកណាហៅថា អារ្យ័ន ។ សាខា
នៃអារ្យ័ននេះ គឺមកបែកគ្នាចូលទៅទ្វីបអឺរ៉ុប និងទ្វីបអាស៊ី ។
សាខាធំមួយដែលបែកចូលទៅខាងលិចទៅទ្វីបអឺរ៉ុប បានទៅ
ជាជនជាតិសេលត៍ (Celtes) ក្រិក (Grecs) ឡាតាំង (Latins)
ហ្សេរម៉ាំង (Germin) និងស្លាវ (Slaves) ។ល។ សាខា

ពំមួយទៀត បែកចូលទៅខាងកើតទៅទ្វីបអាស៊ី បានទៅជា

ជនជាតិអ៉ីរង់ ឬ អ៉ីរាន (Iràn) គឺជនជាតិបារស៊ី , (Parsi)

ដែលនិយាយភាសាហ្សេនដ៍ (Zend) និងជនជាតិហិណ្ឌូដែល

និយាយភាសាសំស្ក្រឹតនៅប្រទេសឥណ្ឌា ។

ពួកអារយ៉ែនដែលតាមខាងទៅខាងទ្វីបអាស៊ី បានរុករាន

ចូលទៅដល់ទន្លេសិន្ធុ (ឥន្ទុស=Indus) គេទៅខាងកើតទៀត

រហូតដល់ទន្លេគង្គា ច្បាំងបណ្ដេញយកទឹកដីជនជាតិដើម ទាំង

ទីឋានលំនៅរកទ្រព្យសម្បត្តិ ធ្វើម្ចាស់ស្រុក យកជនជាតិ

ដើមធ្វើជាទាស បំរើខ្លួន ហើយឲ្យឈ្មោះខ្លួនថា «អារយ៉ែន»

ប្រែថា "អ្នកប្រសើរ" ឲ្យឈ្មោះទីឋានដែលខ្លួនបានថ្មីនេះថា

«អារយាវ័ត៌» ប្រែថា "ទីលំនៅនៃអារយ" ។ តាមប្រវត្តិ-

សាស្ត្រថា ជនជាតិដើមកំណើតស្រុក គឺជនរដ្ឋក៏សិនោះ

ឈ្មោះ "ទ្រាវិឌ" ជាជនមានអារយធម៌ខ្ពង់ខ្ពស់ហើយ កាល

ពួកអារយ៉ែនចូលមករុករានប្រទេសនោះ បានតស៊ូប៊ីដយ៉ាត់ដៃ

តែគស៊ូពុំបាន ដោយពួកកាយ៍ននេះមានគ្រឿងសស្ត្រាវុធខ្លះប្រសើរជាង គឺមានថេចម្បាំងដ៏ពិសាញ ។ ទើបបានជាព្រមទទួលចុះចាញ់ មានខ្លះភៀសខ្លួនគេចរត់ទៅនៅភាគខាងត្បូង ខ្លះទៀតត្រូវពួកកាយ៍នចាប់យកមកធ្វើជាឈ្លើយ ។ ពួកនេះមានច្រើនក្រុមណាស់ មានកុលសម្ពន្ធទស្យុ ឬទាសៈជាដើម ។ សព្វថ្ងៃ "ទស្យុ ឬ ទាសៈ" ដែលគេចាប់ទុកជាឈ្លើយនេះ តមកក្លាយន័យទៅជា "ខ្ញុំបំរើ" ទៅវិញ ។ កុលសម្ពន្ធ ទស្យុ ឬទាសៈនេះ តាមយ៉ិនប្រែកានទុកជា "អរិ" គឺជាសត្រូវនឹងខ្លួន ឬសត្រូវនឹងទេវតារបស់ខ្លួន ។ អ្នកប្រាជ្ញខ្លះហៅទស្យុនេះថាជា "ម៉ិលក្ខុ" ប្រែថា "អ្នកគំ" តែពាក្យនេះ ក្នុងកាលតមក ដោយអ្នកឈ្នះតែងតែមានប្រៀបជាងអ្នកចាញ់ជានិច្ចតា ក៏ក្លាយទៅជាពាក្យទាបថោកហើយមានន័យថាជា "មនុស្សព្រៃ" ទៅវិញ ។ រីឯពាក្យថា ហិណ្ឌូ ឬ ឥណ្ឌា ក៏ជា

ពាក្យទើបកើតថ្មីដែរ   ដូចយើងបានសិក្សាពីខាងដើមរួចមក ហើយ ។

ដល់មកត្រង់នេះ មានប្រស្នាសំខាន់មួយកើតឡើងថា ពួកអាយ៉ែនដែលរុករានចូលមកប្រទេសឥណ្ឌានោះ កាន់លទ្ធិសា-សនាអ្វី? ឯពួកដើមកំណើតស្រុក គឺជនទ្រាវិឌស្ស ឬ ទាសៈ ពុំនោះថា បិលក្ខុ នោះ កាន់លទ្ធិសាសនាអ្វី ?

លោករីស · ដាវិដ ជាអ្នកប្រាជ្ញបាលី ជាអ្នកប្រាជ្ញឯកដ៏ប្រសើរម្នាក់ ក្នុងចំណោមអ្នកប្រាជ្ញទាំងឡាយ ចំពោះវិជ្ជាប្រ-ទេសឥណ្ឌា បានសរសេរពីជនជាតិដើមឥណ្ឌា ទុកថា "គេច្រើនតែចូលចិត្តទុសទួទៅហើយថា ប្រជាជនដើមឥណ្ឌានោះជាជនព្រៃផ្សៃ ដែលពិតនោះមិនមែនជាជនព្រៃផ្សៃ ដូចអ្នកផងឃើញសភាពមនុស្សព្រៃផ្សៃនោះទេ ។ ការដែលគាត់គាស់កកាយមើលបុ-រាណដ្ឋានមុនអាយ៉ែនចូលមក បានបញ្ជាក់ឲ្យឃើញថា មនុស្សដើមកំណើតស្រុកនោះមានសេចក្តីចំរើនហើយ   បានធ្វើយុគថ្ម

គឺសម័យយុគថ្មគ្រើមនិងថ្មរលីង ព្រមទាំងបានចូលយុគស្ពាន់ ដូចជនជាតិហុកណាដែលមកហើយ ។ ក្នុងកាលដែលអាយ៉នបាន ចូលមកនោះ យុគហុកណាសិលា នវសិលា បានបញ្ជាក់ថា ពួកជនដើមកំណើតស្រុកមានភូមិគរ មាននគរហ្លួងនៅត្រឹមត្រូវ ហើយ ពួកខ្លះបានទាំងទ្រព្យសម្បត្តិស្តុកស្តម្ភមាំមួនថែមទៀត សូម្បីតែពួកអាយ៉នឯងក៏មិនទាន់មានដូចទៀតផង ។ សេចក្តីពិត កាលពួកអាយ៉នរុកចូលមកនោះ អ្នកដើមកំណើតស្រុកតស៊ូដែរ ហៅបានតស៊ូខ្លាំងក្លាណាស់ មានកន្លែងខ្លះពួកអាយ៉នចូលទៅមិនបានទេ ហើយក៏បណ្តោយឱ្យពួកដើមកំណើតស្រុកនៅជាឥស្សរភាពតទៅ ។ តែមានភាគច្រើនមិនសូវចង់តស៊ូដោយចង់នៅស្ងប់ ។

ការជីកគាស់កកាយរកទីផ្សេងៗ តាមដងទន្លេសិន្ធុបានឃើញទីក្រុងចាស់ៗ ច្រើនកន្លែង ក្រុងដែលសាងដោយថ្មមានស្នាដៃល្អវិចិត្រ អាយុថ្មប្រាប់ច្បាស់ថាសាងឡើងមុនពួកអា-យ៉នចូលមកដល់ម្ល៉េះ ស្នាដៃកសាងទាំងនេះសំដែងឲ្យឃើញ

ថា អារ្យធម៌របស់ជនជាតិអ្នកដើមកំណើតស្រុកនោះបានឡើងខ្ពង់ខ្ពស់ណាស់ទៅហើយ ។

អ្នកប្រាជ្ញរិះរកជាតិអង់គ្លេសម្នាក់ទៀត ឈ្មោះ ចាហ្ន ម៉ារស្ហល (John Marchal) បញ្ជាក់ថា ក្រុងចាស់ៗ ដែលគេបានជីកកកាយរកឃើញតាមដងទន្លេសិន្ធុទៅ មោហ៊ែនជោ-ដេរោ (Mohan Jo-Dero) និងហារប្បា (Harepp3) នោះសំដែងឲ្យឃើញថា ជនជាតិអ្នកដើមកំណើតស្រុក មានអា-រ្យធម៌ប្រសើរ មានការចេះដឹង មានសេចក្ដីចំរើនក្រៃលែងជាងប្រទេសអ៊ីស៊ីប្ដ ឬកណា និងជាងជនជាតិបុកណាឯទៀត ៗ គឺមេសូប៉ូតាមី (Mésopotamic) ទៅទៀតផង

លោក ជែម ស.មេស្តុន (James S.Meston) អ្នកសិក្សាវិជ្ជាប្រទេសឥណ្ឌា ដែលបានពោលចេញនាមរួចហើយ បញ្ជាក់ថា របស់ពួកអាយ៌នមានវិសេសជាងជនអ្នកដើមកំ-ណើតស្រុកនោះគឺ «វេទម្បាន» ប្រែសេចក្ដីថាពួកអាយ៌នចេះធ្វើកង់រថ ចេះធ្វើរថ ចេះយកសេះទឹម ចេះឈរគោខកាំង

ជិះទៅលើរថ ទេះបររថវិមានដោយសេះមួយ សេះពីរ សេះច្រើន សម្រុកចូលទៅក្នុងកងទ័ពសត្រូវ អ្នកដែលមិនធ្លាប់បានឃើញ ឬដែលមិនធ្លាប់ប្រើវិធីចម្បាំងដូច្នេះ ភ័យរត់ស្ទុះហើយសុខចិត្ត ចាញ់ដោយងាយ ដូចជាចម្បាំងរថក្រោះ ឬ រថកង់ក្នុងសម័យ នេះ ៗ យើងធ្លាប់បានឃើញមកហើយថា ការតែងធ្វើកង់រថនោះ មានការសម្ពន្ធជាប់គ្នានឹងការបូជាព្រះអាទិត្យ ពួកអេយីបដែល ទុកកងបកនោះ ជាអ្នកនាំព្រះអាទិត្យដែលមានរូបដូចកង់រថ (ចក្រ) ចក្រនេះឯងបានកើតទៅជាត្រាសិលាធម៌ មានឈ្មោះថា "ធម្មចក្រ" ។ ដូច្នេះ កង់រថ" តែប៉ុណ្ណោះឯង ដែលធ្វើឲ្យពួក អេយីបទុកកងចូលទៅដណ្ដើមយកប្រទេសឥណ្ឌាបាន ហើយ គ្រប់គ្រងផែនពិភពផែនដីច្រើនកន្លែង ដោយពិសេសវានភាគ លើប្រទេសឥណ្ឌា ឯវិធីរថចម្បាំងនេះ មិនប្រាកដថា ពួក អេយីបមានកេរ្តិ៍ពិសេសឡើយ សូម្បីតែការចម្បាំងលើទូកដែរ ក៏មិនទាន់មានក្នុងកាលនោះដែរ ។

លទ្ធិសាសនារបស់អ្នកដើមកំណើតប្រទេសនោះ មានឡាក់ឃានច្រើនបែបដែលនាំឲ្យជឿថា ជនពួកនោះគោរពបូជាលោកធាតុនិងធម្មជាតិ ៗ លោកធាតុបានដល់ ភ្លើង ខ្យល់ ទឹក ដី ធម្មជាតិបានដល់ ភ្នំ ដើមឈើផ្សេង ៗ ដែលជាចំណែកនៃផែនដី រួមសេចក្ដីទៅថា ពួកជននោះគោរពធាតុទាំងបួន គឺ ដី ទឹក ភ្លើង និង ខ្យល់ ដែលភាសាបារាំងហៅថា Animisme - ជីវពលនិយម គឺប្រកាន់ជឿថា រូបទាំងអស់សុទ្ធតែមានជីវិត មានចិត្ត មានខ្លួនប្រាណ ហើយលើកយកវត្ថុទាំងនេះមកជាទេវតា ហើយសូត្របួងសួងទេវតាទាំងនោះ យកសាច់សត្វ ឬ វត្ថុអ្វីមួយដែលខ្លួនជឿថា ទេវតាពេញចិត្តសព្វសោយ ទៅដាក់ក្នុងគំនរភ្លើង គេជឿទៀតថា ភ្លើងជាទូតរបស់ទេវតា ៗ ការយកដង្វាយទៅដាក់ក្នុងគំនរភ្លើងឲ្យភ្លើងឆេះអស់ទៅនោះ ក្រៅពីការឃើញវត្ថុនោះឆេះអស់រលីងទៅហើយ គេនៅមានសេចក្ដីយល់ថែមទៀតថា

ទេវតាលោកបានសេពសោយផ្កាយខ្ទួនហើយ ។ ឯផ្សែងភ្លើង ដែលហុយទ្រលោមអណ្តែតឡើងទៅលើអាកាសនោះ គេជឿថា បានចូលទៅក្រាបបង្គំទូលដល់ទេវតា ដែលនៅឯឋានសួគ៌ហើយ ។

គំនិតគិតឃើញថាមាន "ឋានសួគ៌" នោះ ជាគំនិតអ្នកដើមកំណើតស្រុករបស់ឥណ្ឌា គេមានយូរមកហើយ មានមុនកាលដែលពួកអារ្យ័នចុះមកម្ល៉េះ គេចូលចិត្តថា "ឋានសួគ៌" នៅលើភ្នំព្រះសុមេរុ ហើយមានរបស់ទាំងនៅកណ្តាលឋានសួគ៌ទិព្វមនុស្សលោក គឺមហាសមុទ្រទឹកឥតសរសៃ ទូកសំពៅចូលទៅមិនបានទេ ព្រោះទឹកនោះល្អិតពេកណាស់ ស្រាលណាស់ ទាល់តែមិនមានអ្វីអណ្តែតនៅលើបាន សូម្បីតែព្រុយក្ងោកដែលអណ្តែតចុះទៅ ក៏ត្រូវលិចចុះទៅបាតដែរ នេះជាគំនិតដែលគេគិត ជាប់តរហូតមកដល់សម័យ រឿងរាមាយណៈ (រាមកេរ្តិ៍) ។ គំនិតនេះមិនមែនជាគំនិតពួកអារ្យ័នទេ ជាគំនិតរបស់ពួកជនអ្នកដើមកំណើតស្រុក ដែលគេមានតាំងតែពីដើម

មកហើយ ៗ រឿងនេះ កើតមានឡើងដោយសារផែនដីធំដែល ជាប្រទេសឥណ្ឌា ក្នុងសម័យបច្ចុប្បន្ននេះ កាលដើមនោះជា កោះធំបហិមា= មហាទ្វីប ទីទំនាប មហានទីសិន្ធុ និងមហានទី ដែលនៅក្នុងមហាទ្វីបនេះ កាលដើមនោះជាឈូងសមុទ្រ ភូមិ ភាគនៅខាងត្បូងឥណ្ឌា ភាគកណ្ដាល និងភ្នំហិមាល័យ ជា សមុទ្រទាំងអស់ ៗ ជនជាតិភារតរស់ តាំងពីបុរាណ យូរអង្វែង ហើយ ក៏ស្គាល់ប្រទេសទ្វីបជាកោះដែរ បានជាគេហៅថា ទ្វីប ឬ ទីបៈ គឺជម្ពូទ្វីប ហើយគេដឹងទៀតថា ក្រោយសមុទ្រ ម្ខាងឯណោះ ជាបព្វតាធំខ្ពស់ត្រដឹងស្កឹមស្កៃឥតគណនា គប- នាគបន់ទៅបករាំងនៃនដភ្នំហិមាល័យ និងភូមិភាគធំនៃឥណ្ឌា នោះ ធ្វើបានដោយលំបាកណាស់ សម្រាប់មនុស្សសម័យ ពីព្រេងនាយ ដោយពិសេសជនឥណ្ឌាដែលជាជនសមុទ្រមក ហើយ កាលពីដើមគង់មានអ្នកធ្លាប់ឆ្លងទៅមកខ្លះដែរ ទៅ ដល់ខ្ពង់ប្រទេសតិបេតធំ ១ ខ្ពស់ស្កឹមស្កៃ ហើយទំនងជាមាន

អ្នកខ្លះប្រើសត្វអូដ្ឋកាយច្រើនផង បានជាមិនសូវមានអ្នកណាហ៊ានផ្ចាញ់ភ័យធ្ងន់ទៅ ម្ល៉ោះហើយក៏សន្មតលើកយកបព៌តហិមាល័យទៅជាឋានសួគ៌ មានសមុទ្រខាងកណ្ដាល ធ្វើឲ្យផ្សេងពីឋានមនុស្សលោក ។ រឿងទាំងនេះ បង្ហាញឲ្យឃើញថាមុនកាលដែលពួកអាយ៌នរុករានចូលទៅក្នុងប្រទេសឥណ្ឌានោះ ជនជាតិស្រុកខាងអាយធម៌ដើមកំណើតស្រុក មានការចេះដឹង មានសាសនា មានទេវតាគោរពបូជារួចទៅហើយ ។

ឯលទ្ធិសាសនាពួកអាយ៌ន ដែលរុករានចូលមកឥណ្ឌានោះ គឺលទ្ធិគោរពកប់អានបូជាព្រះអាទិត្យ ។ ព្រះអាទិត្យនេះ អាយ៌នឲ្យឈ្មោះថាសវិត្ឫ ហើយបានទាំងនាំការគោរពកប់អានបូជាព្រះសវិត្ឫនេះ ចូលមកកាន់ប្រទេសឥណ្ឌាផង ។ ហេតុដែលនាំឲ្យពួកអាយ៌នកប់អានបូជាព្រះអាទិត្យនេះដោយគេសង្កេតឃើញថា ដើរផ្លូវណា មានពន្លឺព្រះអាទិត្យ មានភ្លៀងមានថ្ងៃ ព្រឹក្សាលតាជាតិដុះលូតលាស់ចម្រើនល្អឡើង ព្រឹក្សា

លោកជាតិតែងតែប្រព្រឹត្តទៅ តាមកំដៅព្រះអាទិត្យជាដរាប បានជាពួកអាយ៌នហៅព្រះអាទិត្យថា "សវិត្ឫ" ហៅទឹក ឬទឹកភ្លៀងថា "វរុណ" ហៅទេវតា ដែលបណ្ដាលឲ្យវត្ថុទាំងពួងប្រព្រឹត្តទៅបានក្នុងលោកថា "ឥន្ទ" ហៅទេវតា ដែលចំលាយបំផ្លាញជីវិតមនុស្សនិងសត្វ មិនឲ្យគេចរត់ទៅណាបានថា "យម" ទេវតាទាំងនេះអាយ៌នទុកជា "លោកបាល" ទេវតារក្សាលោក មានពិធីបូជា មានពិធីធ្វើឲ្យលោកបាលពេញព្រះទ័យ ហើយប្រទានសេចក្ដីសុខចម្រើនដល់ខ្លួន ៗ

អាយ៌នដែលគប់អានព្រះអាទិត្យនោះ មិនមានជាប្រស្នាពោធទេ តែការចេះធ្វើកង់រថ ឲ្យបានរថចម្បាំងផ្សាយរំលោបរុករានអាណាខេត្ត ចូលមកទឹកដីឥណ្ឌានោះទើបជាចំណោទ ព្រោះសម្ដែងឲ្យឃើញច្បាស់ថាពួកនេះគប់អានព្រះអាទិត្យមុនមកហើយ ៗ ឯការគប់អានទឹកភ្លៀងទុកជាទេវតា "វរុណ" ឬ "ពិរុណ" នោះ ជាគំនិតដែលកើតឡើងតាមធម្មតាមនុស្ស

ព្រោះភ្លៀងបានធ្វើប្រយោជន៍ដល់មនុស្សពិតប្រាកដ បើមិនមានភ្លៀង មនុស្សទាំងសត្វមិនដឹងជាបានអ្វីមកធ្វើជាអាហារបរិភោគទេ ។ ការគោរពបកេនប្រឹត្យ ឬ យមៈ ក៏ជាគំនិតចាស់បុរាណពីព្រេងនាយដែរ តែជាគំនិតកើតក្នុងកាលក្រោយជំនឿដែលគេជឿថា មានការអ្វើខ្មោចស្លាប់កើត ក្នុងពលផ្ទុ-សង្ស៊ារ ដូចជនបុរាណដទៃទៀតមានជនជាតិរ៉ូស៊ីបុរាណដើម ៗ រឿង "ព្រះឥន្ទ្រ" មានប្រស្នាច្រើនទៀត ដែលគួរលើកយកមកពិចារណាថា តើទេវតានេះកើតមកពីណា ?

បើយើងជឿតាមការពួកអ្នកប្រាជ្ញស្រាវជ្រាវកសម័យថ្មី ដែលស្ដីពីកំណើតទេវតា ហើយនិយាយថា "ម៉ែឪតែងកើតក្រោយកូន" គឺអ្នកសាងតែងតែកើតឡើងក្រោយរបស់ដែលខ្លួនសាងនោះ ដូច្នេះហើយ យើងត្រូវតែជឿទៅទៀតថា សម្រាប់ពួកអាយ៉ន ព្រះឥន្ទ្រជាទេវតា ដែលកើតឡើងក្រោយទេវតាអគ្គិឯទៀត ៗ ទេ ព្រោះអាយ៉ានបានប្រគល់នាទីឲ្យ

ព្រះឥន្ទ្រជាអ្នកសាងលោក ។ លោកហូវ័សអា..ប៉ូលេ. តាំងហាងក្រុមមនុស្សវិទ្យាក្នុងប្រទេសឥណ្ឌា បានសរសេរពីការកសាងលោកក្នុងសម័យអារ្យ៍ននោះទុកថា "ព្រះឥន្ទ្រជាអ្នកកសាងលោក" ដូចសេចក្ដីតទៅនេះ

ក្នុងការកសាងលោក ព្រះឥន្ទ្រគ្រាស់វៃផែនដីមុនដំបូង ហើយរួយទេវតាផងទៃទៀត ក្នុងការលើកសសរឈើធ្វើជាដំបូលលោកនេះឡើង ព្រះព្រហស្បតិ៍ជាអ្នកនាំសសរ ព្រះសវិត្រជាអ្នកបុកដីបង្ហាប់ដើម្បីឲ្យសសរជាប់ ដំបូលលោកនោះ មិនគឺរ៉ូផងទៃទេ គឺវៃរូមេឃនេះឯង ឯសសរដែលព្រះឥន្ទ្រនាំឡើងនោះជាសសរឈើ ។ គំនិតនេះ អ្នកប្រាជ្ញជឿថាជាគំនិតដើមពិត គឺជាគំនិតដែលកើតឡើងតាំងតែពីមនុស្សនៅមិនទាន់ចេះដឹងយកថ្មមកធ្វើជាសសរនៅឡើយ ។

ការកសាងរបស់ព្រះឥន្ទ្រនោះអស្ចារ្យណាស់ គឺគ្រាន់តែនាំសសរឡើង ក៏ធ្វើដំបូលបានតែបួន បិទបាំងបានខ្ទឹម

មិនបាច់មានស្នៀងផ្ទាន ដំបូលមិនធ្លាក់ចុះមកដីទេ ។ វិមានរបស់ព្រះឥន្ទ្រដែលបានពោលនេះ យើងឃើញថាមិនមែនជាវិមានឲ្យមាននិរភ័យបានទេ ព្រោះដំបូលអាចនឹងជ្រុះចុះមកដីពេលណាមួយមិនខាន រឿងនេះ ដូចជាពាក្យបុរាណលោកនិយាយថា «ស្រុកទេសមិនមានមេដំបូល ប្រែសេចក្តីថាប្រជាជនមិនបានសេចក្តីសុខទេ» ។

ព្រះឥន្ទ្រនេះជាទេវតា កើតក្នុងកាលខាងក្រោយពិត គឺ កើតឡើងក្នុងកាលដែលពួកអាយ៌នមានគំនិតថា ត្រូវកសាងលោក ពួកអាយ៌នសាងព្រះឥន្ទ្រនេះឡើង ហើយក៏ប្រគល់នាទីការកសាងលោកឲ្យព្រះឥន្ទ្រ ធ្វើជាធំក្រៃលែង ជាទេវតាបរិបូណ៌ដោយសេចក្តីសុខគ្រប់យ៉ាង ជាងទេវតាទាំងឡាយ តែការឲ្យសម្បូណ៌សប្បាយ ដោយសេចក្តីសុខនេះ ធ្វើឲ្យឋានៈព្រះឥន្ទ្រតន់ថយចុះវិញ ដូចសេចក្តីដែលយើងនឹងឃើញតទៅមុខ ។

មួយទៀត កាលពួកអារ្យ័នចុះមកនោះ ពួកនេះបាន ឃើញជនអ្នកដើមកំណើតស្រុកបូជាភ្លើង ទុកភ្លើងជាវត្ថុសក្តិសិទ្ធិ ។ រឿងនេះ ពួកអារ្យ័នបានឱកាសក៏ប្រាប់ជនអ្នកដើមកំណើតស្រុកថា ភ្លើងដ៏សំខាន់នោះគឺព្រះអាទិត្យ ដែលជាសវិត្ររបស់ខ្លួន ព្រោះព្រះអាទិត្យជាប្រភពកើតភ្លើង គឺជាម្ចាស់នៃភ្លើងទាំងឡាយ ។ ដូច្នេះ ពួកអារ្យ័នបានបង្កើតទេវតាអគ្គិថ្មីមួយទៀតហើយឲ្យឈ្មោះថាព្រះអគ្គិ ទេវតាអគ្គិនេះផ្សេងពីព្រះអាទិត្យ ការបង្កើតទេវតាអគ្គិនេះ បានផលច្រើនប្រការណាស់ ប្រការមួយ គឺ ពេញចិត្តជនអ្នកដើមកំណើតស្រុក ព្រោះគេធ្លាប់បូជាភ្លើងមកហើយ បើពួកអារ្យ័នបានព្រមយកភ្លើងរបស់គេមកជាទេវតាទៀតហើយ គេគិតតែពីសប្បាយចិត្ត ប្រការមួយទៀត បើទុកជាទេវតាអគ្គិកើតឡើង ព្រះអគ្គិនេះ ក៏នៅតែជាទេវតាទាបជាងព្រះអាទិត្យ=សវិត្រ គឺនៅក្នុងឋានៈជាបរិវារព្រះអាទិត្យរបស់អារ្យ័ន ។ នេះហើយ

ជាហេតុសំខាន់មួយធ្វើឲ្យជនអ្នកដើមកំណើតស្រុកដ៏ខ្លួនបាន ខ្លួននៅក្នុងបង្គាប់បញ្ជាពួកអាយ៉ែនដដែល ៗ

មួយវិញទៀត លទ្ធិវេទនៅប្រទេសឥណ្ឌា មានការទាក់ទងគ្នានឹងប្រទេសនេះច្រើនប្រការណាស់ ព្រោះពួកអាយ៉ែនកាលនៅក្នុងប្រទេសនេះនោះ បានគោរពទេវតាច្រើនអង្គ មានឥន្ទ្រៈជាដើម ៗ អ្នកប្រាជ្ញដែលសិក្សាវេទនេះ បានឃើញច្បាស់ថា កាលពួកអាយ៉ែននៅប្រទេសនេះ បានគោរពទេវតាច្រើនអង្គ ដូចទេវតាក្នុងវេទដែរ តែកាលនោះគេមិនទាន់បានចងក្រងគម្ពីរវេទឲ្យបានជាគម្ពីរ មានបែបផែនត្រឹមត្រូវនៅឡើយទេ ៗ

ការដែលពួកអាយ៉ែន ខំព្យាយាមផ្សំផ្សំលទ្ធិសាសនារបស់ខ្លួនឲ្យលាយចូលផ្គុំគ្នាជាមួយលទ្ធិសាសនាជនអ្នកដើមកំណើតស្រុក នេះជាមូលហេតុនាំឲ្យកើតលទ្ធិវេទឡើង ៗ ដូច្នេះ លទ្ធិសាសនាឥណ្ឌា ក៏ដើរចូលទៅកាន់សម័យទី ២

គឺ សម័យវេទៈ ដែលលោកកំណត់ត្រឹមឲ្យរយៈពេលប្រមាណ ជា ១.៥០០ ឆ្នាំ មុនសម័យពុទ្ធកាល ។

សម័យនេះ មនុស្សមានការចេះដឹងប្រសើរជាងពីអតីតកាលខ្លះហើយ មនុស្សយើងចេះយល់ថា មានព្រះទេវតានៅក្នុងឋានសួគ៌ ពួកទេវតាជាអ្នកបង្កើតលោក មនុស្ស សត្វ ទឹក ដី ភ្លើង ខ្យល់ និងវត្ថុទាំងអស់ ហើយមានអំណាចលើវត្ថុទាំងអស់នោះទៀត ការបន់ស្រន់ ស្រូបបួងសួង ក៏ត្រូវតែធ្វើចំពោះពួកទេវតា ដើម្បីឲ្យពួកទេវតាករុណាប្រទានសេចក្ដីសុខសួស្ដីដល់ខ្លួន ដូច្នេះ ការសែនព្រេនស្តុតិចំពោះទេវតា ក៏កើតឡើង ។

២. សម័យវេទ មន្ត្រ សម្រាប់សូត្រស្តុតិចំពោះទេវតា ហៅថា វេទ ។ វេទ ប្រែថា " ការចេះដឹង = Savoir " ជាគម្ពីរព្រាហ្មណ៍ ដែលគេយើងធ្លាប់ដឹងមកហើយថា ត្រៃវិជ្ជា ឬ ត្រៃវេទ មាន ៣ គម្ពីរ តែដែលតាមពិតមាន ៤ គម្ពីរ គឺ :

១- ឫគ្វេទ មន្ត្រៈជាបទឆន្ទ សម្រាប់សូត្រអង្វរករ បន់ស្រន់ បួងសួង ឬ សរសើរបូកបូជាទេវតា ។

២- សាមវេទ ជាបទឆន្ទដែរ សម្រាប់សូត្រ ក្នុងពិធីថ្វាយទឹកសោមចំពោះព្រះឥន្ទ្រ បន្ទន់ចិត្តព្រះឥន្ទ្រ ។

៣- យជុវេទ ជាបទកាយ ស្ដីពីការធ្វើពលិកម្ម និងបួងសួងទេវតា ហើយមានមន្ត្រៈប្រកបផង ។

៤- អថវ៌វេទ ជាគាថាមន្ត្រអាគម ស្នេហ៍ មន្តស័ក្តិសិទ្ធិ អាបធ្មប់ សម្រាប់សូត្រដេញឧបទ្រពចង្រៃ ឬខ្មោចបិសាច នាំឲ្យកើតសិរីសួស្ដីជ័យមង្គលដល់ខ្លួន ព្រមទាំងធ្វើឲ្យផលអាក្រក់ធ្លាក់ទៅលើសត្រូវទៀតផង ។

ការចងក្រងវេទ ធ្វើជាគម្ពីរដោយបរិបូណ៌នេះ តាមពិតមានតែមួយទេ គឺប្រមូលយកមន្ត្រៈសូត្រស្តុតិអង្វរករសរសើរទេវតា យកបទសូត្របន្ទន់ចិត្តព្រះឥន្ទ្រហើយថ្វាយទឹកសោម យកបទកាយដែលស្ដីពីពិធីធ្វើពលិកម្មបួង បួងទេវតាទាំងអស់នេះ មកប្រមូលបញ្ចូលគ្នាធ្វើជាគម្ពីរមួយហៅថា "វេទ" ។

តមក ព្រាហ្មណ៍ជាម្ចាស់វិជ្ជា ដែលមានអាទិក្សធិពិធីទាំងនេះ បានញែកវេទនេះចេញជាគម្ពីរមួយ ៗ ដោយវៀកពីគ្នាដើម្បី ជាការស្រួលប្រតិបត្តិ គឺញែកផ្នែកយកបទសូត្រក្នុងពិធីថ្វាយ ទឹកសោម និងបទសូត្រសរសើរបន្ទន់ចិត្តព្រះឥន្ទ្រ ទុកជា គម្ពីរមួយឲ្យឈ្មោះថា សាមវេទ, ញែកបទកាយដែលស្តីពី ពិធីកម្មបូជាសួងទេវតាទុកជាគម្ពីរមួយទៀតឲ្យឈ្មោះថា យជុ-វេទ ។ លុះញែកចេញដូច្នេះហើយ បទដើមនៅសល់តែជាមន្ត្រៈ គឺឧទ្ទូសរសើរ[illegible]តាទាំងឡាយ ហើយឲ្យឈ្មោះមន្ត្រៈនោះថា ឫគ្វេទ ។ ពាក្យ "ឫក" នេះប្រែថា "សរសើរ" ។ ដូច្នេះវេទ នេះទៅជាមានបីប្រការហៅថា "ត្រៃវេទ" ។ តមកទៀត ពួក ព្រាហ្មណ៍ប្រមូលគាថា មន្ត្រ អាគម ពូកែស័ក្តិសិទ្ធិរបស់អ្នក ស្រុក ដែលមិនមែនជាវេទ តែដែលគេជឿថា បានផលល្អ សម្រាប់ខ្លួនគេ យកមករួបរួមគ្នាធ្វើជាគម្ពីរមួយផ្សេងទៀត ឲ្យ ឈ្មោះថា អថវ៌វេទ ទៅជាវេទមាន ៤ ប្រការ តែគេហៅត្រឹម តែ "ត្រៃវេទ" គេមិនហៅថា "ចតុវេទ" ទេ ។

អ្នកប្រាជ្ញអាល្លឺម៉ង់ម្នាក់ឈ្មោះ ហិល្ល ប្រេន (Hille Brentd) បានប្រែគម្ពីរវេទទាំងអស់ រួមជាមួយអ្នកប្រាជ្ញអាល្លឺម៉ង់ច្រើននាក់ទៀត ដែលចេះវិជ្ជាប្រទេសឥណ្ឌា អ្នកប្រាជ្ញទាំងនេះ កាលគិតគូរពិចារណាហើយ បានសម្តែងសេចក្តីយល់ឃើញថា ការដែលព្រាហ្មណ៍ញែកបទបន្ទន់ចិត្ត ញែកបទភ័យ ចេញទៅជាគម្ពីរនេះ ជាការធ្វើល្អប្រពៃណាស់ ព្រោះថាបើយើងពិចារណាមើលសំនួនវោហារនិងភាសា គ្រប់ទាំងយកការចេះដឹង ដែលកើតពីការស្រាវជ្រាវនៃវេទ ១ ទៀតមកជួយផ្សំផង ក៏ឃើញច្បាស់ថា វេទដើមមានត្រឹមតែជាបទព្រះ គឺ ធម្ម ដែលសល់នៅក្នុងឫគ្វេទតែប៉ុណ្ណោះឯង ឯបទបន្ទន់ចិត្ត គឺសាមវេទនិងបទភ័យ គឺយជុវេទនោះ ជាពាក្យបន្ថែមបញ្ចូលផ្សេងដោយឡែក ៗ នោះយោបីការញែកវេទចេញជា ៣ ប្រការ ឬ ដោយចេតនាដូចម្តេចក៏ដោយ ការនេះ ទុកជាការធ្វើដោយប្រពៃមួយដែរ ឈ្មោះថាបានធ្វើឲ្យគម្ពីរឫគ្វេទសល់

នៅតែចំណែកបរិសុទ្ធតាមដើម គឺថាជា "របស់ចាស់ របស់
បុរាណសុទ្ធ ៗ" ឲ្យកើតមានជំពាក់ប្រាកដឡើង ។

ដោយការពិចារណាអ្នកប្រាជ្ញអឺរ៉ុបដែលបានពោល
មកហើយនេះ យើងឃើញថា គម្ពីរវេទ ឬ ពាក្យឧទ្ទះចិន
សេចក្ដីដែលជាគ្រឿងប្រកបវេទនេះ ពិតជាកើតមានមកតាំង
ពីបុរាណកាលមែន តែមានរូបពេញលក្ខណៈក្នុងកាលជាខាង
ក្រោយ ក្នុងកាលដែលកើតមានរូបតៃណាស្រុកៈវស មានការ
គ្រប់គ្រងត្រឹមត្រូវ មានព្រះកជាណាប្រមុខ មានអ្នកប្រាជ្ញបុរោ-
ហិតជាទីប្រឹក្សាមហសក្ដិព្រះមហាក្សត្រហើយ បើយើងជឿពាក្យ
ថា «មនុស្សសាងលទ្ធិសាសនាឡើងដោយអាស្រ័យវត្ថុ ដែល
យើងបានប្រទះឃើញជាគោលហើយ" យើងក៏គួរជឿសេចក្ដី
យល់ឃើញរបស់អ្នកប្រាជ្ញអឺរ៉ុបក្នុងរឿងនេះដែរ ។

ក្នុងគម្ពីរវេទដែលជាឯកសារចាស់បំផុតនេះ យើងចាប់
សេចក្ដីបានថា ទេវតាដែលធំបំផុតគឺ ព្រះឥន្ទ្រ មានអ្នក

ប្រាជ្ញជាទីប្រឹក្សាវិជ្ជាការគឺព្រះព្រហស្បតិ៍ មានព្រះវរុណគាន់នាទីជាចក្ខុនាយក អ្នកណាធ្វើខុសព្រះវរុណដឹងទាំងអស់ បើមានមនុស្សពីរនាក់ប្រឹក្សាគាត់ក៏ចាំងអ៊ី ព្រះវរុណមកអែបលបចាំស្តាប់ មានព្រះយមៈគាន់នាទីជាកង់រក្ខ សម្រាប់ដាក់ទោសអ្នកដែលប្រព្រឹត្តទុច្ចរិត ក្នុងពេលដែលអ្នកនោះស្លាប់ហើយ តែព្រះយមៈរបស់កេយ៉ាង ផ្សេងគ្នាពីព្រះឧសិរសរបស់ពុទ្ធ មិនពិភាក្សាទួនដេរ នាទីពិភាក្សាទោសលេព្រះសរិទ្ធ ដែលទុកជាសាលាយុត្តិធម៌ ហើព្រះសរិទ្ធពិភាក្សាទៅហើយឃើញថា មានទោស គេបញ្ជូនទៅឲ្យព្រះយមៈធ្វើទោសគេទៀត វិធីនេះទុកជាការគ្រប់គ្រងប្រសើរណាស់ល្មមយល់ថា គេមានការគ្រប់គ្រងល្អហើយ ។

ឯការសាងៈទេវតាទៀងបែបនេះ ក៏ត្រូវសាងទៀងតាមផែនការគ្រប់គ្រងរបស់មនុស្សដែរ គឺព្រះឥន្ទ្រទុកជាព្រះកជាព្រះព្រហស្បតិ៍ទុកជាអ្នកប្រាជ្ញ ជាទីប្រឹក្សារបស់ព្រះអង្គ មាន

ក្រុមព្រះឧត្តរបាល មានសាលាយុត្តិធម៌ មានកងទណ្ឌ ។

ព្រះឥន្ទ្រប្រៀបដូចព្រះមហាក្សត្រាធិរាជ គឺត្រូវជាអ្នកចម្បាំង ក្រាបក្រាមពួកបិសាច ដែលប្រទូស្តមនុស្សជាតិ ពេលពេលដ សំខាន់ធ្វើដោយពេជ្រហៅថា វជ្រាវុធ មានសរ មានព្រះខ័ន មានគទា មានគ្រឿងសម្រាប់ចាប់សត្រូវ មានពាហនៈ គឺដំរី ឰរាវត ជួនកាលទ្រង់ជិះទឹមសេះក្រហម [illegible] ។

ព្រាហ្មណ៍បានសាងសុកប៉ាយព្រះឥន្ទ្រទៀត ជាសុក ដែលធ្វើពីជាតិឈើមួយប្រភេទហៅថា សោមៈ ។ ខាងព្រះឥន្ទ្រជាអ្នកចម្បាំង តែព្រះឥន្ទ្រច្បាំងឈ្នះក៏មាន ចាញ់ក៏មាន មិនសូវតែឈ្នះជាកប់ទេ ដើម្បីឲ្យព្រះឥន្ទ្រចេះតែច្បាំងជានិច្ច ទៅ មិនឲ្យឈប់ឈររហូតតទៅ ។

វិធីប្រតិបត្តិសម័យវេទនេះ មិនមានអ្វីដទៃក្រៅពីការ សែនបួងសួងបូជាទេ គឺ ធ្វើពិធីបូជា ធ្វើតបៈ តែមិនមែនបាន សេចក្តីថាលទ្ធិវេទ ឥតមានសីលធម៌ដ៏ប្រសើរនោះទេ ពាក្យ

សូត្រសរសើរនោះឯងហើយ ជាសីលធម៌នៅក្នុងខ្លួនរបស់ខ្លួន ល្អឬមិនល្អ ក៏មានគ្រោងក្របខណ្ឌនៅក្នុងពាក្យសូត្រសរសើរនោះស្រាប់ហើយ ។

សម័យបំផុតនេះ កើតមានទេវតាខ្ពស់បំផុត មួយអង្គគឺព្រះព្រហ្ម ។ ព្រះព្រហ្មនេះ កើតឡើងបានដូចម្តេច ? ពួកអាយ៌ននេះឯង កាលមានការបេះដូងហើយ មានការបេះគ្រឹះរកហេតុផលហើយ ក៏នឹកគិតឃើញថា ព្រះអាទិត្យ ព្រះចន្ទ ព្រះអគ្និ ព្រះពាយុ ព្រះវរុណ អស់នេះ ម្តេចក៏កើតឡើង ? អ្នកណាបង្កើត ? ដូចខ្លួនឃើញហល់គ្នានេះ កើតមកក៏កើតដោយកាស្រ័យមានមេឪពុក ។ គ្នាមក ចុះទេវតាទាំងនេះអ្នកណាជាមេឪ ? ពួកព្រាហ្មណ៍គិតគ្នាមូលមតិដូច្នេះហើយ ក៏បង្កើតទេវតាធំមួយទៀតឡើងឲ្យឈ្មោះថា "ព្រហ្ម" ។

ព្រះព្រហ្មកើតក្រោយព្រាហ្មណ៍ទេ នេះជាសេចក្តីពិត ៗ អ្នកប្រាជ្ញរិះរកហេតុផលដទៃទៀត ក៏យល់ឃើញស្របគ្នាដែរ

សាស្ត្រាចារ្យអាល្លឺម៉ង់ម្នាក់ គឺលោកស្ត្រូស (Otto Strauss) អធិប្បាយថា សេចក្តីពិតក្នុងគម្ពីរវេទក៏មានប្រាកដហើយថា ត្រូវតែឲ្យមានទេពតាធំបំផុតមួយអង្គ ព្រោះមានត្រឹមតែព្រះឥន្ទ្រមួយអង្គមិនគ្រប់គ្រាន់ទេ មួយទៀតមានពាក្យសូត្រស្តុតិទេពតាច្រើនអង្គ ដែលសាងលោក សាងមនុស្ស គ្រាន់តែមិនចេញឈ្មោះទេពតានោះថា ជាទេពតាអ្វីប៉ុណ្ណោះ ប្រើត្រឹមតែពាក្យថា វិត្វកម៌ន ដែលខ្មែរច្រើនស្គាល់ថា ព្រះវិស្សុកម្ម ទេពតានេះជាអរូបធម៌ គឺ មិនមែនមានរូបកាយទេ គ្រាន់តែជាសភាវធម៌ប៉ុណ្ណោះ ។ លោកជេម ស.មេស្តុន (James S. Meston) អធិប្បាយថា នៅក្នុងសម័យវេទ មនុស្សគុញក្រាប់នឹងព្រះឥន្ទ្រគាន់តែខ្លាំងឡើង ៗ ព្រោះឥន្ទ្រច្បាំងចាញ់គេញយពេក ប្រព្រឹត្តក៏មិនល្អសោះ លបលួចប្រពន្ធកូនគេរឿយ ៗ លួចទាំងប្រពន្ធឫស៊ី គំហែងឫស៊ីគៅត្រ ផឹកទឹកសោមស្រវឹងខ្ទប់ជានិច្ច មនុស្ស អស់ជ្រះថ្លា ក្នុងពេលនេះ

ហើយដែលព្រាហ្មណ៍ព្យាយាមលើកព្រះសវិត្រ៉ឲ្យជាធំឡើង ឯពាក្យថា ប្រជាបតិ គឺលោកមេស្តុនយល់ថាជាឈ្មោះនៃទេពតាសវិត្រនេះឯង ។ នេះជាពាក្យអធិប្បាយអ្នកស្រាវជ្រាវ ដែលបានពិចារណាតប្ដរវែងដោយល្អិត ៗ មានពាក្យអធិប្បាយផ្សេងផងទៀត ជាពាក្យអធិប្បាយរបស់អ្នកប្រាជ្ញអល្ទីម៉ង់ក៏ដែរ គេបានអធិប្បាយទុកថា ការរៀបចំលទ្ធិសាសនាព្រាហ្មណ៍នេះធ្វើតាមវិធីដែលគេរៀបចំស្រុកទេស គឺ កាលពួកអាយ៌នបានចូលបកគ្រប់គ្រងផែនដីឥណ្ឌាហើយ អាយ៌នបែងចែកដីជាផ្នែកគ្នាគ្រប់គ្រង តមកក្នុងកាលជាខាងក្រោយ មានអ្នកខ្លះបានរាព្រះរាជាមានអំណាចធំ បានជាកុជាធិរាជលើព្រះរាជាតាំងឡាយទូទៅ ហើយបង្កើតពាក្យថា "ចក្រពត្តិ" ឡើង ក្នុងពេលនេះលទ្ធិ "អស្វមេធ" ក៏កើតមានក្នុងសាសនាព្រាហ្មណ៍ឡើងដែរ គឺអ្នកណាត្រូវការឲ្យបានជាចក្រពត្រាធិរាជត្រូវលែងសេះឲ្យចូលទៅផែនដង ៗ ហើយលើកទ័ពតាមទៅ

ផែនណាបណ្ដោយឲ្យសេះចូលទៅបាន គេសំគាល់ថា ផែននោះព្រមចុះចូលជាប្រទេសរណបហើយ បើមិនព្រមឲ្យសេះនោះចូលទៅទេ គង់ចាត់ពលដើរទៅតាមក្រោយសេះនឹងចូលលុកលុយផែនដីមកក្លាយ ៗ ប្រពៃណី "អស្សមេធ" នេះមានខ្ចរទៅពេញសាកលជម្ពូទ្វីបក្នុងកាលនោះ ៗ

ឯការគិតសាងទេពតាអង្គថ្មី ១ ឲ្យរឹតតែប្រសើរខ្ពង់ខ្ពស់ពេក ក៏បាន គិតទៅវៀនក្នុងសម័យនេះឯង គឺកើតមុនជាមួយគំនិត ចិនសេចក្ដីព្យាយាមរបស់ក្សត្រ ដែលប្រាថ្នាចង់ឲ្យបានជាចក្រពត្រាធិរាជនេះ ៗ សេចក្ដីនេះបញ្ជាក់ឲ្យឃើញថាលទ្ធិសាសនាវត្តក្នុងសម័យនោះ តែងវិលទៅតាមការបាលនាខាងផ្លូវនយោបាយជាដរាប ៗ ហេតុផលទៅជាដូចម្ដេចក៏ដោយតែព្រាហ្មណ៍បានបង្កើតទេពតាធំបំផុតមួយអង្គ ហើយរិះគិតឲ្យមានឈ្មោះប្រហាក់ប្រហែលគ្នានឹងពាក្យថា "ព្រាហ្មណ៍" ដែលឲ្យសមរម្យនោះ គឺត្រូវឲ្យឈ្មោះថា "ព្រហ្ម" ហើយប្រាប់

ថា "ព្រហ្ម" ជាបុព្វបុរសរបស់ព្រាហ្មណ៍ ។ ក្នុងកាលនោះ ព្រាហ្មណ៍គំរលៀនឋានៈឡើងទៅខ្ពស់ស្មើនឹងទេពតាទាំងឡាយ គឺព្រាហ្មណ៍ជាទេពតានៅនាឋានមនុស្សលោកនេះឯង ។

ការគិតសាងព្រះព្រហ្មនេះ ក៏គេគិតល្អិតល្អន់ណាស់ដែរ គិតថា សាងព្រះព្រហ្មដូចម្ដេចឲ្យបានប្រសើរ ព្រោះគេបានធ្លាប់ធ្វើសាងព្រះឥន្ទ្ររួចហើយ គឺ កាលនោះ សាងព្រះឥន្ទ្រឲ្យបរិបូណ៌ដោយសេចក្ដីសុខគ្រប់ប្រការ ឲ្យមានជាយា ឲ្យមានបរិវារបម្រើរនូវស្ដាំ កប់ទាំងពាន់ ១ ទាល់តែព្រះឥន្ទ្រល្មក់ស្រវឹងតាមល្បប់មុខ ដើរលួចប្រពន្ធគេឯង ប្រព្រឹត្តអនាចារផ្សេងៗ ។ ការសាងព្រះព្រហ្មនេះក្ដី ក៏ត្រូវសាងឲ្យខុសគ្នាពីការសាងព្រះឥន្ទ្រ ព្រោះសាងព្រះឥន្ទ្រខុសទៅហើយ សំខាន់បំផុត គឺសាងព្រះព្រហ្មកុំឲ្យមានប្រពន្ធកុំឲ្យលេងកាម ។ ធ្វើដូចម្ដេចមិនឲ្យមានប្រពន្ធ ? បើសាងឲ្យមានរូបកាយដូចមនុស្ស ឬ ទេពតាដទៃ ១ ក៏ត្រូវតែមានប្រពន្ធទាល់តែបាន

ហើយមានកើតតែច្រើនទៅទៀត ដូចព្រះឥន្ទ្រដូច្នោះឯង ហើយនឹងឲ្យអ្នកយករូបដូចព្រះឥន្ទ្រទៀត បើសាងកុំឲ្យមានប្រពន្ធបានតែម្នាក់ឯង ក៏ត្រូវសាងកុំឲ្យមានរូប គឺមិនឲ្យទៅជារូបធម៌ គ្រាន់តែជានាមធម៌ គិតល្អិតល្អន់យ៉ាងនេះហើយ ក៏សាងព្រះព្រហ្មឡើង មិនមានខ្លួន មិនមានរូប គឺព្រះព្រហ្ម ដែលព្រាហ្មណ៍សាងឡើងថ្មីនេះ គ្រាន់តែជាសភាវធម៌ប៉ុណ្ណោះ ។ ដូច្នេះហើយបានជាកើតប្រយោគឡើងថា "ស្ត្រីជាទោសនៃព្រហ្មចរិយៈ" ក្នុងសាសនាទាំងឡាយនៅប្រទេសឥណ្ឌា ព្រោះដើមហេតុមកពីសាងព្រះឥន្ទ្រឲ្យមានប្រពន្ធច្រើន ។

រឿងទេវតា គឺព្រះឥន្ទ្រដែលនិយាយថា មានប្រពន្ធច្រើន ហើយចេះដើរលួចប្រពន្ធគេឯងទៀតនេះ បើមើលឲ្យសព្វ ៗ ទៅ ព្រះឥន្ទ្រមិនមែនមានឋានៈជាទេវតា នៅលើមេឃទេ ដោយពិតគឺមនុស្សយើងនេះឯង ដែលមានឋានៈជាធំខុសដូចទេវតា ហើយគេឲ្យឈ្មោះថា "ព្រះឥន្ទ្រ=អ្នកធំ"

ហេតុនេះហើយបានជា អ្នកនេះបេះដើរល្បួចប្រពន្ធគេឯង ដូចជាល្បួចប្រពន្ធប្តីជាដើម ជាហេតុនាំឲ្យគេស្អប់ខ្ពើមរហូតដល់គេមិនជ្រះថ្លាគេចង់លុបលោលទៅវិញ ហើយគេបង្កើតអង្គថ្មីទៀតមិនឲ្យមានបេតីបង្កើត "ព្រះព្រហ្មអ្នកប្រសើរ" នេះឯង។

រឿងនេះ ទំនងជាដូច្នេះទេដឹង ?

មួយទៀត "ព្រះព្រហ្ម" នេះ មានមកយូរហើយ ។ ឯព្រហ្មនេះ ជាធម្មៈដែលកើតប្រាកដឡើងក្នុងលោក ព្រោះធម្មៈមិនមានរូបកាយ ។ តែសេចក្តីយល់របស់ព្រាហ្មណ៍ថា ធម្មៈដែលកើតមានឡើងនៅក្នុងលោកនោះ គឺកើតដោយការផ្សំចូលគ្នា ទៅជាស៊ុតមួយ ហើយអណ្តែតនៅក្នុងលោកនេះមួយមុនកល្ប គមក ស៊ុតនោះក៏បែកធ្លាយទៅ ព្រហ្មដែលនៅក្នុងស៊ុតនោះ បណ្តាលឲ្យបែកជាពីរចំហៀង មួយចំ-ហៀងកើតបានជាផ្ទៃអាកាស មួយចំហៀងទៀតកើតបានជាមនុស្សលោក ព្រះព្រហ្មសាងសារពើរក្ត នៅក្នុងឋានសួគ៌

សាងសារពើវត្ថុឲ្យមាននៅឋានមនុស្សលោកនេះ មុនដំបូង សាងជាភ្លើង ឲ្យមកដុតបំផ្លាញរបស់ដែលជាបាបអកុសលឲ្យអស់ទៅ ហើយសាងទឹកទៅលត់ភ្លើងនោះ លុះទឹកនោះលត់ភ្លើងទៅហើយ ទឹកនោះធ្វើឲ្យដីមានជីជាតិ ជាហេតុនាំឲ្យមានការដុះលូតលាស់ មានពូជសារពើវត្ថុ មានស្រូវជាដើមបរិបូណ៌ មានដើមឈើ មានសត្វ មានមនុស្ស កើតពួកមនុស្ស មានមនុស្សម្នាក់ជាកូនព្រះអាទិត្យ កើតឡើងជាស្ដេចផែនដី បានគ្រប់គ្រងប្រជាជនតាំងតែពីកាលនោះមក ។ រួចសេចក្ដីទៅថា ព្រហ្មសាងលោកនេះម្ដងទៀត គឺសាងលោកដែលធ្វើដោយស៊ុត ជំនួសលោកដែលព្រះឥន្ទ្រសាងដោយសសរឈើ មកធ្វើជាគ្រឿងទល់ទ្រដំបូល កាលព្រះព្រហ្មសាងលោកដោយស៊ុតយ៉ាងនេះហើយ រឿងសាងលោករបស់ព្រះឥន្ទ្រនោះ ក៏ទៅជាមោឃអស់ទៅ ។ រឿងនេះព្រាហ្មណ៍អាចផ្សាយប្ដូរតាមពេញចិត្តខ្លួនបានទាំងអស់ ។

មុននឹងចប់រៀនវេទ យើងគួររៀនវេទទី ៤ បន្តិចសិន ។ វេទទី ៤ ឈ្មោះ អថវ៌វេទ ។ វេទនេះ គេមិនដឹងជាក់ច្បាស់ កើតក្នុងកាលណាទេ ហើយបើនឹងទុកដាក់ថាកើតក្នុងពេលណាក៏មិនសម ។ យើងបានដឹងថា ព្រាហ្មណ៍មានឋានៈខ្ពស់ណាស់ គឺមានឋានៈជាមិត្រនឹងទេវតា តមកថា បើបានធ្វើពិធីឲ្យបានត្រឹមត្រូវ អាចមានអំណាចបង្គាប់ទេវតាបានទៀតផង ដោយហេតុតែខ្លួនមានអំណាចសក្តិសិទ្ធិយ៉ាងនេះ ព្រាហ្មណ៍សាងអថវ៌វេទឡើង ដោយការប្រមូលយកវេទមន្តគាថាអាគមសម្រាប់សែនទាំងប៉ុន្មាន ដែលគេជឿថាខ្លាំងពូកែសក្តិសិទ្ធិមានមន្តស្មូត្រដោះគ្រោះ ដេញឧបទ្រពចង្រៃនាំឲ្យកើតសុវត្ថិភាពជាដើម ហើយទេវតានឹងប្រទានឲ្យ បណ្ដាលឲ្យ តាមដែលព្រាហ្មណ៍សុំ ដោយការពោលមន្ត ឬ ដោយពិធីការយ៉ាងណាមួយ ក្រៅពីនេះត្រូវឲ្យពេញចិត្តទេវតា ដូចពោលមកហើយនេះ នៅមានការធ្វើឲ្យលាញទៀត ដូចជាមន្តស្នេហ-

សាស្ត្រ កប់រូប កប់ស្មារតី ឬ ធ្វើស្នេហ៍ឲ្យស្រលួយចិត្តកើតក្តីស្រឡាញ់ ពុំនោះធ្វើឲ្យកែចិត្តទៅជាខូចបែកជាដើម នេះហើយជាគម្ពីរជាន់ក្រោយ ដែលព្រាហ្មណ៍ជឿថា អាចធ្វើឲ្យទេពតា ក្តៅក្រហាយបានដោយមន្ត្ររបស់ខ្លួន ។

សម័យវេទនេះ ផុតរលត់សាបរលាបទៅមួយអន្លើដោយការកើតព្រះត្រៃវេទ តទៅ លទ្ធិសាសនាព្រាហ្មណ៍បានឈានចូលទៅដល់សម័យទី ៣ គឺសម័យព្រាហ្មណៈ ដែលបានឈ្មោះមកពីព្រហ្ម ។

## ៣- សម័យព្រាហ្មណៈ–កាលព្រាហ្មណ៍បង្កើតព្រះព្រហ្មបានហើយ ក៏ប្រកាសប្រាប់ប្រជាជនខ្លួនទៅថាព្រះព្រហ្មនេះ ជាទេពតាខ្ពង់ខ្ពស់ផុត ការសំខាន់បំផុត គឺព្រះព្រហ្មមិនមានភេទ គ្រាន់តែជាសភាវធំ មិនមានកូនមិនមានប្រពន្ធ មិនចេះបរិភោគកាមគុណ ប្រជាជនពេញចិត្ត ព្រោះឃើញថាវិសេសជាងព្រះឥន្ទ្រមែន ដោយខ្លួនស្អប់ខ្ពើមព្រះ

ត្រូវណាស់ តែដែលថាព្រះព្រហ្មមិនមានរូបនេះ ប្រជាជនមិនសូវពេញចិត្តទេ ព្រោះគេមិនអាចនឹងគោរពសការធម៌ដែលមើលមិនឃើញនោះបាន ។ តមក ពួកព្រាហ្មណ៍ប្រកាសប្រាប់ប្រជាជនទៀតថា បានគេឃើញហើយ សេចក្តីពិតព្រះព្រហ្មមានរូប មានមុខ ៤ មើលទៅកាន់ទិសទាំង ៤ បាន មើលឃើញលោកគ្រប់ជ្រុងបាន តែមិនមានប្រពន្ធទេ ។

ព្រះព្រហ្មកើតឡើងដូចម្តេចក៏ដោយ លក្ខណៈដូចម្តេចក៏ដោយ តែការសាងព្រះព្រហ្មឡើងនេះ មានផលប្រសើរណាស់ ព្រោះជាការបដិវត្តន៍ក្នុងផ្លូវសាសនា ដែលជាប្រភពឲ្យកើតសិទ្ធព្រាហ្មណ៍ឡើងគឺ :

១– ធ្វើឲ្យកើតធម៌វិសេសរបស់មនុស្ស គឺ ព្រហ្មចរិយៈ
២– ធ្វើឲ្យកើតលទ្ធិអាត្មន ជាលទ្ធិខ្ពស់ក្រៃលែងក្នុងសាសនាព្រាហ្មណ៍
៣– ធ្វើឲ្យកើតលទ្ធិឧបនិស័ទ ជាលទ្ធិជាន់ឯកក្នុងសាសនាព្រាហ្មណ៍ ។

១–ព្រហ្មបរិយៈ– ការបិទផ្លូវ មិនឲ្យព្រះព្រហ្មមាន

ប្រពន្ធនេះ ធ្វើឲ្យកើតគំនិតប្រសើរមួយ គឺធ្វើឲ្យមនុស្ស យល់ឃើញថា កាមគុណជាធម៌លាមក ពួកព្រាហ្មណ៍ កាលដើមដូចជនធម្មតាខ្លះទៅ មានប្រពន្ធមានកូន ប្តីជាព្រាហ្មណ៍ ប្រពន្ធជាព្រាហ្មណី ដូចគ្រួសារធម្មតា ហើយប្រកបកសិកម្មបានទៀតផង កាលបើយកព្រះព្រហ្មមិនឲ្យមានប្រពន្ធ គឺមិនពាក់ព័ន្ធនឹងកាមគុណ គឺជាគុណប្រសើរណាស់ ព្រោះជាហេតុនាំឲ្យពួកព្រាហ្មណ៍ខ្លះពេញចិត្ត ប្រព្រឹត្តតាមបែបបទព្រះព្រហ្ម ទើបកើតទៅជាព្រាហ្មណ៍មាន ២ ប្រភេទ គឺ

១- សមណព្រាហ្មណ៍ ព្រាហ្មណ៍ជាសមណៈ ប្រព្រឹត្តព្រហ្មចរិយធម៌ មិនមានប្រពន្ធ មិនពាក់ព័ន្ធដោយកាមគុណ នៅដោយឡែកតែម្នាក់ឯង ៗ

២- គហបតិព្រាហ្មណ៍ ព្រាហ្មណ៍ពួកដើម នៅគ្រប់គ្រងផ្ទះ មានប្រពន្ធ មានកូន ប្រកបកសិកម្ម ធ្វើជំនួញ ធ្វើស្រែចំការ ដូចជនធម្មតាខ្លះទៅ ៗ

នេះហើយជាប្រភពនាំឲ្យកើតស្ថាប័នដ៏ធំក្រៃលែងហៅថា
ចរិយៈ ប្រែថា "ការប្រព្រឹត្តិដូចព្រហ្ម ឬការប្រព្រឹត្តិឲ្យ
ទៅកើតជាព្រហ្ម" ជាស្ថាប័នដ៏ប្រសើរវិសេស ហើយមាន
ពលចូលទៅក្នុងសាសនាដទៃទៀតផង ព្រោះជាបដិបទា
ប្រសើរ ដ៏បរិសុទ្ធ ៗ រីឯខ្មែរយើងក៏ហៅអ្នកបរិសុទ្ធមិនទាក់
ទងដោយកាមគុណនេះថា "ព្រហ្មចារី" ដែរ ៗ ការលះកាម-
គុណចេញទៅបួសនៅដោយឡែកម្នាក់ឯង ជាការលះប្រសើរ
បំផុត ៗ កាលដើម មានតាបសបុស្សីដែរ តែជាតាបសបុស្សី
ខាងគរិហេ បានជាមានរឿងរ៉ាវណាហេថា ព្រះឥន្ទ្រទៅលប
លួចគរិយាបុស្សី តែស្ថាប័នថ្មីនេះ ប្រសើរវិសេសជាងមុន
ពន់ពេកមែន ព្រោះកើតទៅជាសច្ចធម៌ ៗ ការបដិវត្តន៍នេះ ទុកជា
វិធីប្រសើរមួយនៃប្រវត្តិសាស្ត្រឥណ្ឌា មានមនុស្សលះបង់ទ្រព្យ
សម្បត្តិ លះគ្រួសារ លះយកសសុខ ចេញទៅនៅម្នាក់
ឯង មិនទាក់ទងនឹងកាមគុណ ជាបុគ្គលវិសេសពិត គួរហៅថា

ព្រហ្មចារី គេបានទទួលការគោរពបូជាពីគ្រប់ថ្នាក់ ។ គេ
ស្គាល់ព្រះព្រហ្មឡើង ជាត្រឹមការណ៍សំខាន់ណាស់ ទុកជា
ចលនាមួយដ៏ធំក្រៃលែងនៃសម័យព្រាហ្មណ៍ គឺប្រទេសឥណ្ឌា
មានផលមិនចំពោះតែខាងសាសនាទេ បានផលដល់ប្រទេស
ជាតិ និងជីវិតរបស់ប្រជាជនក្នុងទាំងមូល គឺមនុស្សបានជួបវិធីដ៏
ប្រសើរមួយ ដែលសាងខ្លួនដោយបរិពិតបរិសុទ្ធហើយស្ងប់ ដូច
យើងបានដឹងថា មានភក្តបុរស ការសម្បត្តិបោះបង់ចោលចេញទៅ
ប្រព្រឹត្តព្រតជាបព្វជិត ប្រគល់កាយថ្វាយដើម្បីការទូន្មាន
ប្រៀនប្រដៅមនុស្សទាំងឡាយ ហើយបានជាគណាចារ្យគ្រូ
ទីសំណាក់ការនៅទីផ្សេងៗគ្នា តាមលទ្ធិខ្លួន មានបរិវារស្ដាប់
ទទួល ប្រាជ្ញាសេចក្ដីសុភាសិត ។

២-លទ្ធិអាត្មន - អាត្មន (A.Soul, F.Ame) នៃពួកយើង
ពីបុរាណប្រែថា "ព្រលឹង" អធិប្បាយបានដោយលំបាក
ណាស់ ៗ សេចក្ដីថា អាត្មនគឺព្រះព្រហ្ម ជាមជ្ឈដ្ឋាននៃសារ

តើវត្ថុទាំងឡាយក្នុងលោកនេះ ព្រះព្រហ្មសាងលោក សាងមនុស្ស សាងសារពើវត្ថុ តែមិនមែនសាងដោយនិម្មិតដូចព្រះការិទេពនៃលទ្ធិហេព្រ៊ិវ ព្រះព្រហ្មសាងដោយយកសារពើវត្ថុដែលចេញទៅពីព្រះព្រហ្ម ដូចព្រលឹងមនុស្សសត្វ គឺដួងព្រលឹងរបស់ព្រះព្រហ្ម ដែលបែងចេញទៅមិនចេះអស់ឡើយ បែងទៅកើតជាមនុស្ស ជាសត្វ ជាដើមឈើ ជាសារពើវត្ថុ ខ្លួនយើងនេះ ក៏មកពីព្រះព្រហ្មដែរ ព្រះព្រហ្មក៏គឺខ្លួនយើង ខ្លួនយើងក៏គឺព្រះព្រហ្ម បើចង់ស្គាល់ព្រះព្រហ្ម ក៏ត្រូវព្យាយាមរៀនស្គាល់ខ្លួនយើង បើស្គាល់ខ្លួនយើងច្បាស់ហើយ ឈ្មោះថាស្គាល់ព្រះព្រហ្មហើយ បើយើងចូលទៅដល់ខ្លួនយើងបានពិតហើយ នោះឈ្មោះថា យើងបានចូលទៅដល់ព្រះព្រហ្មហើយ ។

អាត្ម័ន ជាឯកភាព គឺវត្ថុទាំងពួងនៅតែមួយ វត្ថុតែមួយគឺ វត្ថុទាំងអស់ មនុស្សទាំងអស់ សូម្បីផ្សេងគ្នា ក៏មិន

មែនមកពីណាផ្សេងទេ មកតែពីព្រះព្រហ្មដូចគ្នាទាំងអស់ គួរមានមេត្តាករុណាដល់គ្នានិងគ្នា ព្រោះមកតែពីតែមួយពិត ។ មនុស្សនិងព្រះព្រហ្ម មិនមែនពីរ មិនមែនគូទេ តែជិតគ្នាណាស់ ព្រោះជាខ្លួនរបស់ខ្លួនឯង ព្រះព្រហ្មគឺខ្លួនយើង ខ្លួនយើងគឺព្រះព្រហ្ម ដូច្នេះ លទ្ធិអាត្ម័ន គឺលទ្ធិ "ខ្លួនឯង" ។ បើនឹងប្រៀបធៀបឲ្យច្បាស់លាស់ទៅទៀត ត្រូវប្រៀបព្រះព្រហ្ម ដូចមហាសមុទ្រ ប្រៀបមនុស្ស សត្វ ដើមឈើនិងវត្ថុសារពើទាំងឡាយដូចទឹក ។ ទឹកគ្រប់ដំណក់ មិនថាដំណក់ទឹកណាទេ ដំណក់ភ្លៀង ដំណក់ទឹកសន្សើម ស្ទឹងទន្លេ បឹងបួ ដំណក់ទឹកក្នុងដី ដំណក់ទឹកនៅគ្រប់កន្លែង ដែលមនុស្សផឹកឬមុជ រហូតដល់ទឹកដែលស្មោកគ្រោក ទាំងអស់នេះ សុទ្ធតែមកពីមហាសមុទ្រទាំងអស់ ដូច្នេះ ដំណក់ទឹកសន្សើម ដែលនៅលើស្លឹកស្មៅជាកូនរបស់ទឹកមហាសមុទ្រឬអ្វី ? ថានេះ មិនមែនទេ មិនមែនកូន មិនមែនពីរទេ

ជាទឹកដូចគ្នា ទឹកក្នុងមហាសមុទ្រក៏គឺដំណក់ទឹកសន្សើមនេះឯង ដំណក់ទឹកសន្សើមគឺទឹកមហាសមុទ្រនេះឯងដែរ មិនត្រូវនិយាយថា ទឹកក្នុងមហាសមុទ្រ ជាម៉ែរបស់ដំណក់ទឹកសន្សើមក៏ឥតអង្គមានឡើយ ត្រូវតែនិយាយថា ដំណក់ទឹកសន្សើមក៏គឺទឹកមហាសមុទ្រនោះឯង ជារបស់តែមួយជាមួយគ្នា ជាឯកភាពគឺជារបស់ "ខ្លួនឯង" នេះ ត្រូវគ្នាចំនឹងពាក្យជា "អាត្មន" ដែលប្រែថា "ខ្លួនឯង" ហើយខ្មែរយើងហៅថា "ព្រលឹង" ។

លទ្ធិអាត្មននេះ ដែលពីបានទៅជាព្រលឹងរបស់មនុស្ស ឬសត្វ ដែលមកពីព្រហ្មហើយ ទីបំផុតព្រលឹងទាំងអស់នេះក៏វិលត្រឡប់ទៅកាន់ព្រហ្មវិញ សេចក្ដីនេះ គេប្រកាន់ជឿថា ជាបរមសុខ ជាសេចក្ដីបរិសុទ្ធ ជាការរួចស្រឡះដែលហៅថា "មោក្ស=ការរួចស្រឡះ" ព្រោះគេយល់ថា កាលបើព្រលឹងត្រឡប់ចូលទៅកាន់ព្រហ្មបានវិញហើយ ព្រលឹងមិនត្រូវមាន